ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)
独立行政法人　国際協力機構




# សេចក្តីសង្ខេបអំពីកិច្ចសហប្រតិបត្តិការនៅកម្ពុជា

២០១៥-២០១៦



*ហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុនក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតបាននាំមកនូវភាពរីករាយនិងសុខភាពល្អដល់កុមារកម្ពុជា (រូបថតដោយ កេនស៊ី្ញ អ៊ីម៉ាមូរ៉ា)*

# មាតិកា


បុព្វកថា ........................................................ ១
តើទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ជាអ្វី? .... ២
សាវតានៃសហប្រតិបត្តិការរបស់ JICA នៅកម្ពុជា...................... ៤
យុទ្ធសាស្ត្រសហប្រតិបត្តិការ និងវិស័យអាទិភាពរបស់ JICA .......... ៥
វិស័យអាទិភាពទី ១ ការពង្រឹងមូលដ្ឋានគ្រឹះសេដ្ឋកិច្ច.................. ៦
វិស័យអាទិភាពទី ២ ការលើកកម្ពស់ការអភិវឌ្ឍសង្គម ................. ៨
វិស័យអាទិភាពទី ៣ ការពង្រឹងអភិបាលកិច្ច.......................... ១១

# បុព្វកថា

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានកំពុងខិតខំប្រឹងប្រែងធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាមានលក្ខណៈកាន់តែប្រសើរឡើង ចាប់តាំងពីការបញ្ជូនអ្នកស្ម័គ្រចិត្តមកប្រទេសកម្ពុជាជាលើកដំបូងក្នុងឆ្នាំ១៩៦៥ និងការចាប់ដំណើរការការិយាល័យក្នុងរាជធានីភ្នំពេញក្នុងឆ្នាំ១៩៩៣។ នៅដំណាក់កាលដំបូងនៃការសហការអភិវឌ្ឍន៍នៅកម្ពុជា ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុនផ្តោតសំខាន់ទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗឡើងវិញដើម្បីសម្រួលដល់ការរស់នៅរបស់ប្រជាជន ព្រមទាំងការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងវិស័យជាច្រើន សំដៅសម្រេចអោយបាននូវការអភិវឌ្ឍធនធានមនុស្សរយៈពេលវែង។ ឧទាហរណ៍ជាក់ស្តែង ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុនដែលផ្តល់តាមរយៈ JICA ក្នុងរយៈពេលជាងពីរទសវត្សកន្លងមកនេះមានឥទ្ធិពលជាវិជ្ជមានដល់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។ ប្រទេសដទៃក៏បានដឹងឮពីការគាំទ្រនេះដែរ ព្រោះប្រទេសកម្ពុជាបានក្លាយជាអ្នកជួយដល់ប្រទេសដទៃទៀត ក្នុងវិស័យសំខាន់ៗដូចជា ការដោះមីន និងការផ្គត់ផ្គង់ទឹកស្អាតជាដើម។

សព្វថ្ងៃនេះនៅលើចំណុចប្រសព្វនៃការអភិវឌ្ឍដ៏គួរឲ្យកត់សម្គាល់របស់ប្រទេសកម្ពុជា ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការជប៉ុនអនុវត្តដោយ JICA ត្រូវបានតម្រឹមឡើងវិញជានិច្ចផ្អែកតាមការប្រែប្រួលនៃតម្រូវការរបស់កម្ពុជា។ JICA បានបង្កើនការយកចិត្តទុកដាក់លើការផ្សារភ្ជាប់ទំនាក់ទំនងនៃការអភិវឌ្ឍទាំងក្នុង និងក្រៅ ទាំងលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពរបស់កម្ពុជាតាមរយៈមធ្យោបាយដូចជាការដោះស្រាយបញ្ហានគរូបនីយកម្ម និងកែលម្អបរិយាកាសពាណិជ្ជកម្ម ដើម្បីជម្រុញការវិនិយោគ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងកសាងធនធានមនុស្សដែលត្រូវការចាំបាច់សម្រាប់ឧស្សាហូបនីយកម្ម ខណៈដែលហិរញ្ញប្បទាននៅតែបន្តក្នុងវិស័យអាទិភាពសំខាន់ទាំងបីដូចជា (១) ការពង្រឹងមូលដ្ឋានគ្រឹះសេដ្ឋកិច្ច (២) ការជម្រុញការអភិវឌ្ឍសង្គម និង (៣) ការពង្រឹងអភិបាលកិច្ច។

ខណៈប្រទេសកម្ពុជាកំពុងបន្តអភិវឌ្ឍន៍ "គុណភាព" គឺជាពាក្យគន្លឹះក្នុងការសហការអភិវឌ្ឍន៍របស់ JICA ក្នុងវិស័យជាច្រើនរួមមានហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម សុខាភិបាល អប់រំ អភិបាលកិច្ច បរិស្ថាន ការវិនិយោគ និងភាពជាដៃគូ។ JICA មានជំនឿយ៉ាងមុតមាំថា ឧត្តមភាពប្រៀបធៀបនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍របស់ខ្លួន ស្ថិតនៅលើការប្តេជ្ញាចិត្តខ្ពស់ ក្នុងការសម្រេចអោយបាននូវផ្លែផ្កានៃការអភិវឌ្ឍ ដែលប្រកបដោយគុណភាពសម្រាប់ប្រជាជនកម្ពុជាដោយការសហការជាមួយពួកគាត់។

តាមរយៈការអនុវត្តកិច្ចសហប្រតិបត្តិការជាមួយនឹងប្រទេសកម្ពុជាដោយប្រើប្រាស់មធ្យោបាយហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ និងធនធានទាំងឡាយដែលមាន JICA នឹងបន្តខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តបន្ថែមទៀត ក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដែលមានគុណភាពខ្ពស់ អាចសម្រេចបាននូវការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌ និងដើរតួជាស្ពានដ៏រឹងមាំក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រជាជន និងប្រទេសទាំងពីរ។



**អាដាជី អ៊ីតស៊ុ**
ប្រធានតំណាង
ទីភ្នាក់ងារសហប្រតិបត្តិការ
អន្តរជាតិជប៉ុនប្រចាំកម្ពុជា

## បុគ្គលិកការិយាល័យ JICA ប្រចាំកម្ពុជា



# តើទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ជាអ្វី ?

## ស្ពានសម្រាប់តភ្ជាប់ប្រទេសជប៉ុន និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍

JICA * គឺជាទីភ្នាក់ងារប្រតិបត្តិនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុនដែលជួយ និងគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលពួកគេកំពុងជួបប្រទះ។ មូលនិធិដែលប្រើជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការជប៉ុន បានមកពីការបង់ពន្ធរបស់ប្រជាជនជប៉ុន ។

JICA ទទួលបន្ទុកអនុវត្តហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការទ្វេភាគីភាគច្រើនរបស់ជប៉ុន ដូចជា សហប្រតិបត្តិការបច្ចេកទេស កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ និងហិរញ្ញប្បទានឥតសំណងដោយមាន លក្ខណៈស៊ីសង្វាក់គ្នា ។

បច្ចុប្បន្ន JICA ជាទីភ្នាក់ងារផ្តល់ហិរញ្ញប្បទានទ្វេភាគីធំជាងគេនៅលើពិភពលោក មានវត្តមាននៅជាង ១៥០ ប្រទេស និងមានទីតាំងការិយាល័យក្រៅប្រទេសជិត ១០០ កន្លែង ។

* នៅប្រទេសជប៉ុន JICA ជាស្ថាប័នមានស្វ័យភាពផ្នែករដ្ឋបាល




* ទាំងនេះមិនរាប់បញ្ចូលហិរញ្ញប្បទានឥតសំណងដែលអនុវត្តដោយផ្ទាល់ ដោយក្រសួងការបរទេសជប៉ុននៅក្នុងលក្ខណៈការទូត

## តើហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការជប៉ុនជាអ្វី ?

ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ គឺជាជំនួយផ្នែកហិរញ្ញវត្ថុ និង/ឬ ផ្នែកបច្ចេកទេសដែលរដ្ឋាភិបាលនានាផ្តល់ទៅឲ្យប្រទេសកំពុងអភិវឌ្ឍន៍ ជាផ្នែកមួយនៃសហប្រតិបត្តិការសេដ្ឋកិច្ច * ។

ចាប់តាំងពីឆ្នាំ១៩៥៤ ប្រទេសជប៉ុនបានបន្តផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការក្នុងគោលបំណង ដើម្បីចូលរួមចំណែកដល់ការកសាងសន្តិភាព និងការអភិវឌ្ឍរបស់ពិភពលោក។ ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការជប៉ុន ត្រូវបានបែងចែកយ៉ាងទូលាយ ក្នុងរូបភាពជាហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគីដែលត្រូវបានផ្តល់ផ្ទាល់ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងហិរញ្ញប្បទានសហប្រតិបត្តិការពហុភាគីដែលត្រូវបានផ្តល់ឲ្យតាមរយៈអង្គការអន្តរជាតិនានា។ JICA ផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគីនៅក្នុងទម្រង់កិច្ចសហប្រតិបត្តិការបច្ចេកទេស កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ និងហិរញ្ញប្បទានឥតសំណង។

* និយមន័យនេះកំនត់ដោយគណៈកម្មាធិការហិរញ្ញប្បទានអភិវឌ្ឍន៍នៃអង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និង អភិវឌ្ឍន៍ត្រូវគោរពគោលការណ៍ចំនួន ០៣ ដូចខាងក្រោម ៖

- ត្រូវអនុវត្តដោយរដ្ឋាភិបាល ឬភ្នាក់ងាររដ្ឋាភិបាល
- គោលបំណងចម្បង គឺការជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច និងការលើកកម្ពស់សុខុមាលភាពប្រជាជន នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍
- ត្រូវមានលក្ខណៈសម្បទាន ដោយមានធាតុហិរញ្ញប្បទានឥតសំណងយ៉ាងតិច ២៥%

**សម្គាល់** ៖ ធាតុហិរញ្ញប្បទានឥតសំណងបង្ហាញពីកម្រិតសម្បទាន (ភាពទន់ភ្លន់) នៃលក្ខខណ្ឌហិរញ្ញវត្ថុរបស់កម្ចី។ ប្រសិនបើអត្រាការប្រាក់កាន់តែទាប និងរយៈពេលសងត្រឡប់ទៅវិញកាន់តែយូរ ធាតុហិរញ្ញប្បទានឥតសំណងមានកម្រិតកាន់តែខ្ពស់ មានន័យថាវាកាន់តែមានប្រយោជន៍ដល់អ្នកខ្ចី។ សម្រាប់ហិរញ្ញប្បទានឥតសំណង គឺមានធាតុហិរញ្ញប្បទានឥតសំណងស្មើ១០០% ។

# វិធីសាស្ត្ររបស់ JICA ក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ

### កិច្ចសហប្រតិបត្តិការបច្ចេកទេស

នៅក្នុងការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងប្រព័ន្ធរដ្ឋបាល របស់ប្រទេសកំពុងអភិវឌ្ឍន៍ កិច្ចសហប្រតិបត្តិការបច្ចេកទេសមានរូបភាព ដូចជា ការបញ្ជូនជំនាញការ ការផ្តល់គ្រឿងបរិក្ខារ និងបណ្តុះបណ្តាលបុគ្គលិក មកពីបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅក្នុងប្រទេសជប៉ុន និងនៅក្នុងប្រទេសដទៃទៀត។ ផែនការសហប្រតិបត្តិការបច្ចេកទេសអាចត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយបញ្ហា និង ឆ្លើយតបនឹងតម្រូវការនានារបស់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។



ជំនាញការ JICA កំពុងពន្យល់សមភាគីកម្ពុជា (រូបថតដោយ កេនស៊ី អ៊ីម៉ាម៉ូរ៉ា)

### កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ

កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានកម្រិតចំណូលជាក់លាក់មួយចំនួន តាមរយៈកម្ចីដែលមានការប្រាក់ទាបមាន រយៈពេលសងយូរ និង មានលក្ខណៈសម្បទាន ដើម្បីផ្តល់ហិរញ្ញវត្ថុសម្រាប់ ការអភិវឌ្ឍប្រទេសរបស់ពួកគេ។ កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការត្រូវបានប្រើប្រាស់ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធធំៗ និងការអភិវឌ្ឍផ្សេងៗទៀត ដែលត្រូវការហិរញ្ញប្បទានច្រើន។ ក្នុងករណី ប្រទេសកម្ពុជាលក្ខខណ្ឌការប្រាក់មានតម្លៃ ០,០១% មានរយៈពេលសងត្រឡប់ទៅវិញ ៤០ ឆ្នាំ និង មាន រយៈពេលអនុគ្រោះ ១០ ឆ្នាំ ។

សម្រាប់គ្រប់គម្រោង សហប្រតិបត្តិការហិរញ្ញប្បទានកម្ចីអភិវឌ្ឍន៍ផ្លូវការជប៉ុន ទីប្រឹក្សាគម្រោង និងអ្នកសាងសង់ ត្រូវបានគេជ្រើសរើស ដោយសម្រិតសម្រាំង តាមរយៈនិតិវិធីប្រកួតប្រជែងមានលក្ខណៈអន្តរជាតិដែលដឹកនាំអនុវត្តដោយប្រទេសអ្នកខ្ចី។ មានក្រុមហ៊ុនក្នុងស្រុកមួយចំនួននៅក្នុងប្រទេសអ្នកខ្ចីចូលរួមដំណើរការនេះ ។



ចំណតពហុបំណងកំពង់ផែក្រុងព្រះសីហនុ

### ហិរញ្ញប្បទានឥតសំណង

ហិរញ្ញប្បទានឥតសំណង គឺជាការផ្តល់នូវហិរញ្ញប្បទាន ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានកម្រិតចំណូលទាបដោយមិនមានកាតព្វកិច្ចសងត្រឡប់ទៅវិញ។ ហិរញ្ញប្បទានឥតសំណងត្រូវបានប្រើ ដើម្បីកែលម្អហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជា សាលារៀន មន្ទីរពេទ្យ រោងចក្រផ្គត់ផ្គង់ទឹកស្អាត ផ្លូវថ្នល់ ជាមួយនឹងការថែទាំសុខភាពនិងការថែទាំវេជ្ជសាស្ត្របរិក្ខារ និងតម្រូវការផ្សេងទៀត។



ស្ពានជ្រោយចង្វា (រូបថតដោយ ស៊ែហ្សាន ចាន់នី)

### កិច្ចសហប្រតិបត្តិការតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ

*JICA អនុវត្តកិច្ចសហប្រតិបត្តិការរបស់ខ្លួនដោយលើកទឹកចិត្តឲ្យមានការចូលរួមពីប្រជាជនជប៉ុនរួមទាំងការបញ្ជូនអ្នកស្ម័គ្រចិត្ត។*

(សម្រាប់ព័ត៌មានពិស្តារ សូមមើលទំព័រទី១២ និង១៣)

# ទស្សនៈវិស័យរបស់ JICA

## ការអភិវឌ្ឍដែលប្រកបដោយថាមភាពនិងការចូលរួម

មានបញ្ហាជាច្រើននៅលើពិភពលោកដែលមិនអាចដោះស្រាយដោយប្រទេសនីមួយៗបាន ប៉ុន្តែត្រូវដោះស្រាយរួមគ្នាដោយសហគមន៍ពិភពលោក។ ដើម្បីដោះស្រាយបញ្ហាទាំង នេះ JICA បានកំណត់នូវទស្សនៈវិស័យរបស់ខ្លួន គឺ "ការអភិវឌ្ឍដែលប្រកបដោយថាមភាពនិងការចូលរួម" ក្នុងគោលបំណងដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍដែលជម្រុញឲ្យប្រជាជន ទាំងអស់ ទទួលស្គាល់នូវបញ្ហាអភិវឌ្ឍន៍ដែលពួកគេជួបប្រទះផ្ទាល់ ចូលរួមដោះស្រាយបញ្ហាទាំងនោះ ព្រមទាំងរីករាយជាមួយនឹងផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងទាំងនេះ។ តួនាទីរបស់ JICA គឺត្រូវសម្រួលដល់ដំណើរការនេះឲ្យមានប្រសិទ្ធភាព។ ដើម្បីសម្រេចទស្សនៈវិស័យនេះ JICA អនុវត្តប្រតិបត្តិការ តាមខ្លឹមសារបេសកកម្មចំនួន ០៤ និងយុទ្ធសាស្ត្រសំខាន់ចំនួន ០៤ ។

| បេសកកម្ម | | | |
|---|---|---|---|
| ១. ដោះស្រាយរបៀបវារៈសកល<br>ការដោះស្រាយរបៀបវារៈសកលមានដូចជាការប្រែប្រួលអាកាសធាតុ ទឹក ស្បៀងអាហារ ថាមពល ជំងឺឆ្លង និងការផ្តល់ហិរញ្ញប្បទាន ។ | ២. ការកាត់បន្ថយភាពក្រីក្រតាមរយៈកំណើនប្រកបដោយសមធម៌<br>បន្តការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព តាមរយៈកំណើនដែលមានការចូលរួម និងប្រកបដោយសមធម៌ ។ | ៣. ការកែលម្អអភិបាលកិច្ច<br>ពង្រឹងគោលនយោបាយ ស្ថាប័ន ការគ្រប់គ្រង និងធនធានមនុស្សជាឆ្អឹងខ្នងនៃការអភិវឌ្ឍ ។ | ៤. ការសម្រេចឲ្យបាននូវសន្តិសុខដល់មនុស្សជាតិ<br>ការការពារសុវត្ថិភាព មនុស្សជាតិពីការគម្រាមកំហែង និងការកសាងសង្គមដែលពួកគេ អាចរស់នៅប្រកបដោយភាពថ្លៃថ្នូរ ។ |
| **យុទ្ធសាស្ត្រ** | | | |
| ១. ជំនួយដែលមានលក្ខណៈចម្រុះ<br>បញ្ចូលគ្នានូវការគាំទ្រគោលនយោបាយ ការកសាងស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាដើម។ ជំនួយតំបន់ និងអន្តរវិស័យ ។ | ២. ហិរញ្ញប្បទានដែលបន្តមិនចេះដាច់<br>ការផ្តល់ជំនួយឲ្យបានឆាប់រហ័ស និងបន្តបន្ទាប់ ចាប់ពីជំនួយសង្គ្រោះបន្ទាន់ដល់ការស្តារនិងការកសាងប្រទេសឡើងវិញ និងការកសាងសន្តិភាព។<br>គោរពតាមតម្រូវការអភិវឌ្ឍន៍ដោយមានលក្ខណៈបត់បែនតាមដំណាក់កាលអភិវឌ្ឍន៍ជាក់លាក់ ចាប់ពីប្រទេសអភិវឌ្ឍន៍តិចតួច ដល់ប្រទេសដែលមានប្រាក់ចំណូលមធ្យម ។ | ៣. ការលើកកម្ពស់ភាពជាដៃគូក្នុងកិច្ចការអភិវឌ្ឍន៍<br>ការលើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន។ អនុវត្តបច្ចេកវិទ្យា និងចំណេះធ្វើ។ ពង្រឹងភាពជាដៃគូក្នុងចំណោមសហគមន៍អ្នកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ ។ | ៤. ការពង្រឹងការស្រាវជ្រាវ និងការចែករំលែកចំណេះដឹង<br>ការពង្រឹងភារៈកិច្ចនៃការស្រាវជ្រាវស្តីពីកិច្ចអភិវឌ្ឍន៍ តាមរយៈការទាញយកនូវបទពិសោធន៍ជាក់ស្តែងជាច្រើនរបស់ JICA ។<br>ការចែករំលែករបកគំហើញនៃការស្រាវជ្រាវព្រមទាំងដឹកនាំកិច្ចពិភាក្សានានា ស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ ។ |

# ទំហំប្រតិបត្តិការរបស់ JICA

នៅក្នុងឆ្នាំ២០១៣ ហិរញ្ញប្រទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការសរុបរបស់ប្រទេសជប៉ុនមានចំនួន ១.៦៥៥,៦ ពាន់លានយេន។ ហិរញ្ញប្រទានសហប្រតិបត្តិការសរុបរបស់ JICA ទូទាំងពិភពលោកនៅក្នុងឆ្នាំសារពើពន្ធ ២០១៤ មានដូចខាងក្រោម៖

កិច្ចសហប្រតិបត្តិការបច្ចេកទេសមានចំនួន ១៧៦,៤ ពាន់លានយេន និងកម្ចីហិរញ្ញប្បទានសហប្រតិបត្តិការមានចំនួន ១.០១៥,៩ ពាន់លានយេន និងមានកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង ចំនួន ១១១,២ ពាន់ លានយេន។

ក្រាហ្វិក១ - ហិរញ្ញប្រទានសហប្រតិបត្តិការសរុបរបស់ JICA ក្នុងឆ្នាំសារពើពន្ធជប៉ុន២០១៤




*ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០១៥ របស់ JICA*

# លំហូរប្រតិបត្តិការរបស់ JICA

JICA អនុវត្តយ៉ាងមានប្រសិទ្ធភាព និងប្រសិទ្ធិផលនូវហិរញ្ញប្បទានសហប្រតិបត្តិការក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញប្បទានរបស់រដ្ឋាភិបាលជប៉ុន ដែលមាន លក្ខណៈទូលំទូលាយ និងអាចធ្វើឲ្យគម្រោងហិរញ្ញប្បទាននីមួយៗមានភាពស៊ីសង្វាក់គ្នា។ JICA ធ្វើសហប្រតិបត្តិការទាំងនេះ ដោយការសហការយ៉ាងស្អិតរមួតជាមួយនឹងរដ្ឋាភិបាលជប៉ុន និងរដ្ឋាភិបាលទទួលផលពីហិរញ្ញប្បទានសហប្រតិបត្តិការ នៅក្នុងគ្រប់ដំណាក់កាលនៃវដ្តរបស់គម្រោង ។




* JICA អនុវត្តការវាយតម្លៃគម្រោងដោយប្រើប្រាស់វដ្តនៃសកម្មភាពគ្រប់គ្រង ធ្វើផែនការ-អនុវត្ត-ត្រួតពិនិត្យ-កែតម្រូវ (PDCA Cycle) សម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ ហិរញ្ញប្បទានឥតសំណង សំដៅពង្រឹងគុណភាពប្រតិបត្តិការរបស់ខ្លួន និងគណនេយ្យភាពចំពោះសាធារណជន។

# សារតានៃកិច្ចសហប្រតិបត្តិការរបស់ JICA នៅក្នុងកម្ពុជា

| ឆ្នាំ | ព្រឹត្តិការណ៍ |
|---|---|
| ឆ្នាំ១៩៥៤ | ការបង្កើតទំនាក់ទំនងរវាងជប៉ុន និងកម្ពុជា |
| ឆ្នាំ១៩៦៥ | កិច្ចព្រមព្រៀងនៃការបញ្ជូនអ្នកស្ម័គ្រចិត្តរវាងប្រទេសជប៉ុន និងកម្ពុជា (ឆ្នាំ១៩៦៦ អ្នកស្ម័គ្រចិត្តត្រូវបានបញ្ជូនមកកម្ពុជា) |
| ឆ្នាំ១៩៦៩ | ការចុះកិច្ចសន្យាលើកិច្ចព្រមព្រៀងកម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការលើកដំបូងរវាងកម្ពុជា និងជប៉ុន |
| ឆ្នាំ១៩៩៣ | ការបង្កើតការិយាល័យសម្របសម្រួលអ្នកស្ម័គ្រចិត្ត និងដំណើរការការិយាល័យ JICA ប្រចាំនៅកម្ពុជា |
| ឆ្នាំ២០០៨ | ការរួមបញ្ចូលគ្នារវាង JICA និង JBIC |
| ឆ្នាំ២០១៣ | ខួប២០ឆ្នាំរបស់ JICA ប្រចាំនៅកម្ពុជា |
| ឆ្នាំ២០១៥ | ខួប៥០ឆ្នាំរបស់ JOCV |

JICA បានចាប់បដិសន្ធិនៅឆ្នាំ១៩៩៣ ជាការិយាល័យសម្របសម្រួលសម្រាប់អ្នកស្ម័គ្រចិត្តវ័យក្មេងនិងអ្នកស្ម័គ្រចិត្តវ័យចំណាស់។ ក្រោយមកនៅក្នុងឆ្នាំ ១៩៩៤ JICA បានចាប់ផ្តើមដំណើរការពេញលេញក្នុងការប្រតិបត្តិការហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុន។ ជាង៣០ឆ្នាំមុនពេលបើកការិយាល័យតំណាងនៅកម្ពុជាអ្នកស្ម័គ្រជនជាតិជប៉ុនត្រូវបានបញ្ជូនមកប្រទេសកម្ពុជាដំបូងក្នុងឆ្នាំ១៩៦៥បន្ទាប់មកក្នុងឆ្នាំ ១៩៦៩ រាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលជប៉ុនបានសម្រេចកិច្ចព្រមព្រៀងកម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការសម្រាប់គម្រោងអភិវឌ្ឍន៍ថាមពលនិងប្រព័ន្ធធារាសាស្ត្រ។ គម្រោងទាំងនោះត្រូវបានផ្តល់ហិរញ្ញប្បទានដោយមូលនិធិសហប្រតិបត្តិការសេដ្ឋកិច្ចក្រៅប្រទេសដែលបានធ្វើសមាហរណកម្មទៅជាធនាគារជប៉ុនសម្រាប់សហប្រតិបត្តិការអន្តរជាតិ (JBIC) ក្នុងឆ្នាំ១៩៩៩ ហើយនៅក្នុងឆ្នាំ ២០០៨ JBIC ត្រូវបានរួមបញ្ចូលគ្នាជាមួយ JICA ។

ឆ្នាំ២០១៣ គឺជាខួប៦០ឆ្នាំនៃទំនាក់ទំនងការទូតរវាងប្រទេសជប៉ុននិងប្រទេសកម្ពុជា។ គិតត្រឹមឆ្នាំ២០១៣ JICA បានកំពុងធ្វើការជាមួយប្រជាជននៅក្នុងប្រទេសកម្ពុជា អស់រយៈពេលជាង២០ឆ្នាំមកហើយ។

# ការចូលរួមចំណែកដល់ប្រទេសកម្ពុជា

ចាប់តាំងពីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅក្នុងឆ្នាំ១៩៩១ ប្រទេសជប៉ុនបានចូលរួមយ៉ាងសកម្មនៅក្នុងការកសាងឡើងវិញនិងការអភិវឌ្ឍប្រទេសកម្ពុជារួមទាំងការបញ្ជូននូវកងកម្លាំងទាហ៊ានមិនប្រយុទ្ធរបស់ជប៉ុន ប៉ូលីសស៊ីវិល និងអ្នកសង្កេតការបោះឆ្នោតនៅក្នុងការចូលរួមអនុវត្តប្រតិបត្តិការបេសកកម្មរក្សាសន្តិភាពរបស់អង្គភាពសហប្រជាជាតិលើកដំបូងរបស់ជប៉ុនមកកាន់ប្រទេសកម្ពុជា។

ចាប់តាំងពីឆ្នាំ ១៩៩២ មកប្រទេសជប៉ុនបានក្លាយជាដៃគូអភិវឌ្ឍន៍ទ្វេភាគីឈានមុខគេនៅក្នុងប្រទេសកម្ពុជាហើយ JICA បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ដោយផ្តល់នូវហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការតាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេស កម្ចីសម្បទាន និងហិរញ្ញប្បទានឥតសំណង។ រហូតមកត្រឹមឆ្នាំ២០១៣ហិរញ្ញប្បទានសរុបដែលបានផ្តល់ដល់កម្ពុជា មានប្រមាណជា ២.៣៧៤ លានដុល្លារសហរដ្ឋអាមេរិក។

នៅដើមទសវត្សរ៍ទី៩០ ដោយសារស្ថានភាពក្រោយសង្គ្រាមនៅប្រទេសកម្ពុជាមានភាពលំបាកហិរញ្ញប្បទានឥតសំណង គឺជាមធ្យោបាយហិរញ្ញប្បទានដ៏ចម្បងរបស់ប្រទេសជប៉ុនសម្រាប់ប្រទេសកម្ពុជា។ប៉ុន្តែនៅក្នុងឆ្នាំ១៩៩៩ JICA បានបន្តការផ្តល់កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការដើម្បីឆ្លើយតបនឹងតម្រូវការហិរញ្ញវត្ថុក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមានសារៈសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចដ៏ខ្លាំងក្លានិងប្រកបដោយចីរភាពរបស់កម្ពុជា។ គិតត្រឹមដើមឆ្នាំ២០១៥ JICA បានសន្យាផ្តល់កម្ចីសម្បទានដែលមានចំនួនសរុបជាង ៨៦,៦ ពាន់លានយ៉េន។

ក្រាហ្វិកទី២បង្ហាញថាជប៉ុនបានកំពុងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការដល់ប្រទេសកម្ពុជាមានបរិមាណច្រើនគួរឲ្យកត់សម្គាល់នាប៉ុន្មានឆ្នាំថ្មីៗនេះ។

ជំនាញការជប៉ុនដែលមានទាំងការអប់រំខ្ពស់និងបទពិសោធន៍វិជ្ជាជីវៈនៅក្នុងវិស័យផ្សេងៗជាច្រើនត្រូវបានបញ្ជូនមកដើម្បីធ្វើការរួមគ្នាជាមួយប្រជាជននិងរាជរដ្ឋាភិបាលកម្ពុជា។លើសពីនេះចាប់តាំងពីដំណើរការរបស់ខ្លួននៅប្រទេសកម្ពុជាមក JICA បានបញ្ជូនសិក្ខាកាមកម្ពុជាជាច្រើន ជារៀងរាល់ឆ្នាំចូលរួមវគ្គបណ្តុះបណ្តាលតាមជំនាញឯកទេសផ្សេងៗទៀត។ តាមរយៈកម្មវិធីបណ្តុះបណ្តាលទាំងនេះសិក្ខាកាមកម្ពុជាបានទទួលនូវជំនាញនិងចំណេះដឹងច្បាស់លាស់ដែលចាំបាច់សម្រាប់អភិវឌ្ឍន៍កម្ពុជា។ បច្ចុប្បន្នមានអតីតកម្មសិក្សាការីជាច្រើន កំពុងធ្វើការយ៉ាងស្វាហាប់ជាសកម្មជនអភិវឌ្ឍន៍ជំនាន់ថ្មីក្នុងវិស័យរបស់ពួកគេ។

ក្រាហ្វិក២- ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុនផ្តល់ដល់កម្ពុជាតាមប្រភេទនៃកិច្ចសហប្រតិបត្តិការ




*ប្រភព៖ ទិន្នន័យអំពីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា(មិនា ឆ្នាំ២០១៤)*

ក្រាហ្វិក៣- កម្ចីសម្បទានរបស់ជប៉ុនសម្រាប់កម្ពុជាក្នុងបណ្តាឆ្នាំថ្មីៗ (ការសន្យា)




*ប្រភព៖ សហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ឆ្នាំ២០១៥*



*ត្រីដែលចាប់បានដោយកសិករទទួលផលនៃគម្រោងអភិវឌ្ឍន៍និងផ្សព្វផ្សាយវារីវប្បកម្មទឹកសាប (រូបថតដោយ កេនស៊ី អ៊ីម៉ាមូរ៉ា)*



*កសិករកំពុងពិនិត្យគុណភាពស្រូវច្រូតហើយ*



*កូនសិស្សធ្វើដំណើរទៅសាលាដោយសុវត្ថិភាពតាមបណ្តោយផ្លូវជាតិលេខ១ (រូបថតដោយ កូជី សាតូ)*

# យុទ្ធសាស្ត្រសហប្រតិបត្តិការ និងវិស័យអាទិភាពរបស់ JICA

## សម្រាប់កំណើនសេដ្ឋកិច្ចដែលប្រកបដោយថាមភាព និងមានចីរភាព និងការអភិវឌ្ឍប្រកបដោយគុល្យភាព

ដើម្បីសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររាជរដ្ឋាភិបាលកម្ពុជាបានបង្កើតយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលជាយុទ្ធសាស្ត្រអភិវឌ្ឍន៍មានលក្ខណៈស៊ីជម្រៅ ដើម្បីឈានទៅសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា។

ស្របទៅនឹងយុទ្ធសាស្ត្រទាំងឡាយដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា រដ្ឋាភិបាលជប៉ុន បានកែសម្រួលនូវគោលនយោបាយហិរញ្ញប្បទានសហប្រតិបត្តិការរបស់ខ្លួនសម្រាប់ប្រទេសកម្ពុជា នៅក្នុងឆ្នាំ ២០១២ និងបង្កើតជាគោលដៅរួមសម្រាប់ប្រតិបត្តិការនៅកម្ពុជា ។

ដោយយោងទៅតាមគោលនយោបាយហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ប្រទេសកម្ពុជា JICA បានកំណត់គោលបំណងហិរញ្ញប្បទានរយៈពេលមធ្យមសម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជារួមមាន (ការសម្រេចឲ្យបាននូវសន្តិសុខមនុស្សជាតិតាមរយៈកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ) និងផ្តោតសំខាន់លើវិស័យអាទិភាពចំនួនបីសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួន គឺ ( ទី១ ) ការពង្រឹងមូលដ្ឋានគ្រឹះសេដ្ឋកិច្ច ( ទី២ ) ការលើកកម្ពស់ការអភិវឌ្ឍសង្គម និង ( ទី៣ ) ការពង្រឹងអភិបាលកិច្ច។

ស្ថិតក្រោមវិស័យអាទិភាពទាំងនេះ និងយោងទៅតាមការវិភាគនាពេលថ្មីៗនេះអំពីបញ្ហាប្រឈមក្នុងការអភិវឌ្ឍជាមួយបរិបទនៃសេដ្ឋកិច្ចសង្គមបច្ចុប្បន្ន JICA កំពុងប្រើប្រាស់គ្រប់ទម្រង់ទាំងអស់នៃហិរញ្ញប្បទានអភិវឌ្ឍន៍របស់ជប៉ុនដើម្បីធ្វើការបោះជំហានទៅរកគោលបំណងនៃការអភិវឌ្ឍដែលបានកំណត់ ដោយគោរពនូវភាពជាម្ចាស់នៃការអភិវឌ្ឍដែលដឹកនាំដោយរាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជាផងដែរ។ លើសពីនេះ JICA សហការយ៉ាងសកម្មជាមួយដៃគូសំខាន់ៗជាច្រើនរួមមានដៃគូអភិវឌ្ឍន៍ដែលមានស្រាប់និងដៃគូអភិវឌ្ឍន៍ថ្មី ព្រមទាំងវិស័យឯកជនក៏ដូចជាអង្គការសង្គមស៊ីវិលនានា ដែលមានជំនាញនៅក្នុងវិស័យរបស់ខ្លួន។



# ការពង្រឹងមូលដ្ឋានគ្រឹះសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាកើនឡើងគួរឲ្យកត់សម្គាល់ នាទសវត្សចុងក្រោយនេះ។ អត្រាកំណើនផលិតផលជាតិសរុបប្រចាំឆ្នាំមានកម្រិតលើសពី១០ភាគរយក្នុងកំឡុងពេលពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៧។ បន្ទាប់ពីកំណើននេះ ត្រូវបានអាក់ខានដោយសារវិបត្តិហិរញ្ញវត្ថុសកលលោក នៅក្នុងឆ្នាំ ២០០៩មក សេដ្ឋកិច្ចកម្ពុជាបានកើនឡើងវិញយ៉ាងឆាប់រហ័ស។ នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទីបីដែលបានប្រកាសដាក់ឲ្យប្រើប្រាស់នៅ ក្នុងខែកញ្ញា ឆ្នាំ២០១៣ រាជរដ្ឋាភិបាលកម្ពុជាតាំងចិត្តសម្រេចឲ្យបាននូវអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម ៧ភាគរយនៅក្នុងឆ្នាំក្រោយៗទៀត ដោយការធ្វើពិពិធកម្មមូលដ្ឋានគ្រឹះសេដ្ឋកិច្ចបន្ថែមទៀត តាមរយៈយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឯកជន និងឧស្សាហូបនីយកម្ម។ ក្នុងន័យនេះ រាជរដ្ឋាភិបាល មានគោលបំណងបង្កើតមូលដ្ឋានគ្រឹះសេដ្ឋកិច្ច សំដៅសម្រេចបាននូវទស្សនៈវិស័យរយៈពេលវែងដើម្បីឈានទៅរកប្រទេសដែលមានចំណូលមធ្យមត្រឹមឆ្នាំ ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។ ការសម្រេចបាននូវទស្សនៈវិស័យនេះតម្រូវឲ្យប្រទេសកម្ពុជាត្រូវមានហេដ្ឋារចនាសម្ព័ន្ធប្រសើរ ជាងមុន ពង្រឹងវិស័យកសិកម្ម និងការអភិវឌ្ឍវិស័យឯកជនដែលតម្រូវឲ្យមានការវិនិយោគលើផ្នែកធនធានមនុស្ស ដើម្បីទទួលបាននូវជំនាញសមស្រប។

## ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច

**១១%**
**(២៥០គម/២២៤០គម)**
នៃផ្លូវជាតិមួយខ្នង់ត្រូវបានក្រាលកៅស៊ូ ដោយហិរញ្ញប្បទានសហប្រតិបត្តិការ អភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុន

JICA បានរួមចំណែកអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជាជាយូរណាស់មកហើយរហូតមកដល់បច្ចុប្បន្ន រួមមានទាំងការអភិវឌ្ឍ ផ្លូវថ្នល់ ស្ពាន កំពង់ផែ អគ្គិសនី និងប្រព័ន្ធទូរគមនាគមន៍។ សម្រាប់ការអភិវឌ្ឍ ផ្លូវថ្នល់ និងស្ពានJICAបានផ្តោតកិច្ចសហប្រតិបត្តិការរបស់ខ្លួនទៅលើបណ្តាញផ្លូវជាតិសំខាន់ៗដែលរងការបំផ្លិចបំផ្លាញធ្ងន់ធ្ងរនៅក្នុងរបបប៉ុលពត។ លើសពីនេះដើម្បីពង្រឹងការផ្សារភ្ជាប់ ក្នុងតំបន់ទន្លេមេគង្គ JICA បានកំពុងនិងជួយគាំទ្រក្នុងការអភិវឌ្ឍច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងតាមរយៈការស្តារឡើងវិញផ្លូវជាតិលេខ១ (ហិរញ្ញប្បទានឥតសំណងក្នុងទំហំទឹកប្រាក់៩៣.៧៣០លានយ៉េន)ការសាងសង់ស្ពានត្សឹបាសា(ស្ពានអ្នកលឿង)(ហិរញ្ញប្បទានឥតសំណងចំនួន ១១.៩៤០ លានយ៉េន) និងស្តារឡើងវិញនូវផ្លូវជាតិលេខ៥ (កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ និងធ្លាប់បានឯកភាពក្នុងទំហំទឹកប្រាក់ ២៩.៧៥៩លានយ៉េន) ដែលអាចតភ្ជាប់ប្រទេសវៀតណាមនិងប្រទេសថៃ តាមរយៈរាជធានីភ្នំពេញ។ នៅក្នុងវិស័យដឹកជញ្ជូននៅក្នុងទីក្រុង JICA បានរៀបចំផែនការមេសម្រាប់វិស័យដឹកជញ្ជូននៅរាជធានីភ្នំពេញសម្រាប់ឆ្នាំគោលដៅ ២០៣៥ តាមរយៈ "គម្រោងសិក្សាទូលំទូលាយស្តីពីផែនការមេលើការងារដឹកជញ្ជូនក្នុងរាជធានីភ្នំពេញ" (កិច្ចសហប្រតិបត្តិការបច្ចេកទេស) និង "គម្រោងសម្រាប់ការអភិវឌ្ឍការគ្រប់គ្រងប្រព័ន្ធចរាចរណ៍នៅរាជធានីភ្នំពេញ" (ហិរញ្ញប្បទានឥតសំណងក្នុងទំហំទឹកប្រាក់ ១.៧២៧លានយ៉េន) ដែលកំពុងត្រូវបានអនុវត្ត ហើយដែលជាគម្រោងអាទិភាពក្នុងចំណោមគម្រោងអាទិភាពផ្សេងទៀតដែលបានកំណត់នៅក្នុងផែនការមេ។



ស្ពាន ត្សឹបាសា (ស្ពានអ្នកលឿង) (ថតរូបដោយ អាយ៉ាគុរ គីមីរា)

សម្រាប់ការអភិវឌ្ឍកំពង់ផែ JICA បានចាប់ផ្តើមកិច្ចសហប្រតិបត្តិការរបស់ខ្លួនចាប់តាំងពីឆ្នាំ ១៩៩៦ មក តាមរយៈកម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ សម្រាប់គម្រោងស្តារឡើងវិញកំពង់ផែក្រុងព្រះសីហនុ។ រហូតមកទល់បច្ចុប្បន្នមានគម្រោងសហប្រតិបត្តិការចំនួន១០ (០៤ គម្រោងជាកិច្ចសហប្រតិបត្តិការបច្ចេកទេស ០៥ គម្រោងជាកម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ និង ០១ គម្រោងជាហិរញ្ញប្បទានឥតសំណង) ដែលកំពុងត្រូវបានអនុវត្តនៅកំពង់ផែក្រុងព្រះសីហនុ។ ជាលទ្ធផលនៃការអនុវត្តមធ្យោបាយជំនួយផ្សេងៗគ្នាទាំងបីខាងលើ និងកិច្ចសហការយ៉ាងជិតស្និទ្ធ បាននាំមកនូវភាពល្អប្រសើរទាំងគ្រឿងបរិក្ខារ និងសេវាកម្មនៅក្នុងកំពង់ផែអន្តរជាតិមួយនេះ។

ដោយឡែកនៅក្នុងវិស័យអគ្គិសនី JICA បានចូលរួមចំណែកក្នុងការធ្វើឲ្យអគ្គិសនីមានតម្លៃថោក និងការផ្គត់ផ្គង់មានស្ថិរភាពតាមរយៈគម្រោងអភិវឌ្ឍន៍បណ្តាញអគ្គិសនីក្នុងមហាតំបន់ទន្លេមេគង្គ (កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការក្នុងទឹកប្រាក់ចំនួន ២.៦៣២លានយ៉េន) និងគម្រោងពង្រីកប្រព័ន្ធបញ្ជូននិងចែកចាយអគ្គិសនីនៅរាជធានីភ្នំពេញ (កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ ជំហានទី១ មានទឹកប្រាក់ចំនួន ៦.៤៨០លានយ៉េន និងជំហានទី២ មានទឹកប្រាក់ចំនួន ៣.៨១៦លានយ៉េន) ក៏ដូចជាការអនុវត្តគម្រោងហិរញ្ញប្បទានឥតសំណង និងគម្រោងកិច្ចសហប្រតិបត្តិការបច្ចេកទេសដែលមានភាពប្រទាក់ក្រឡាគ្នាផងដែរ។



ពិធីសម្ពោធបើកដំណើរការតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែស្វយ័តក្រុងព្រះសីហនុ (រូបថតដោយ អាយ៉ា គឹមូរ៉ា)

នៅក្នុងវិស័យទូរគមនាគមន៍ ប្រទេសកម្ពុជាបានទទួលការគាំទ្រពី JICA តាមរយៈ គម្រោងការបង្កើតបណ្តាញទូរគមនាគមន៍ឆ្អឹងខ្នងមហាតំបន់អាងទន្លេមេគង្គ (កម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការមានចំនួន ៣.០២៩លានយ៉េន) ដែលនឹងតម្លើងខ្សែកាបអុបទិចប្រវែង ៤០០គីឡូម៉ែត្រ និងឧបករណ៍ផ្សេងៗ ដើម្បីតភ្ជាប់បណ្តាញទូរគមនាគមន៍ដែលមិនទាន់មានពីក្រុង ព្រះសីហនុដល់ខេត្តកំពង់ចាម ។

## វិស័យឯកជន



មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន

ឧស្សាហកម្មកាត់ដេរ និងវិស័យទេសចរណ៍បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជម្រុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលជាងមួយទសវត្សចុងក្រោយនេះ។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្នប្រទេសកម្ពុជាចាំបាច់ត្រូវធ្វើពិពិធកម្មមូលដ្ឋានផលិតកម្មរបស់ខ្លួន តាមរយៈឧស្សាហូបនីយកម្ម ដោយបង្កើតអោយមានតម្លៃបន្ថែមខ្ពស់ និងជម្រុញពាណិជ្ជកម្ម ពីព្រោះរចនាសម្ព័ន្ធឧស្សាហកម្មបច្ចុប្បន្នមិនទូលំទូលាយនិងងាយរងគ្រោះដោយសារការពឹងពាក់ខ្លាំងទៅលើតម្រូវការរបស់ទីផ្សារបរទេស។ ការសម្របសម្រួលដើម្បីអោយទទួលបាននូវធនធានហិរញ្ញវត្ថុវិនិយោគគ្រប់គ្រាន់ក្នុងប្រទេស ការបង្កើតផលិតភាពក្នុងស្រុក ការជួយសម្រួលបន្ថែមដល់ការផ្ទេរបច្ចេកវិទ្យាខាងផលិតកម្មដល់ឧស្សាហកម្មក្នុងស្រុកនិងការជម្រុញការវិនិយោគផ្ទាល់ពីបរទេស សុទ្ធតែជាកំលាំងចលករក្នុងការបង្កើតកាលានុវត្តភាពការងារបន្ថែមទៀតដើម្បីឲ្យកម្ពុជា អាចសម្រេចបាននូវដំណាក់កាលផ្លាស់ប្តូរនៃឧស្សាហកម្មដូចរៀបរាប់ខាងលើនេះ។ ក្នុងពេលជាមួយគ្នានេះភាពប្រកួតប្រជែងរបស់ឧស្សាហកម្មក្នុងស្រុកនិងរបស់អង្គភាពអាជីវកម្មធុនតូច និងមធ្យម គួរត្រូវបានពង្រឹងបន្ថែមទៀត។ លើសពីនេះទៅទៀត ធនធានមនុស្សនៅក្នុងឧស្សាហកម្មប្រភេទនេះគួរត្រូវបានអភិវឌ្ឍន៍បន្ថែមទៀតដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងនេះ ឲ្យកាន់តែប្រសើរឡើងជាងមុនទៀត។

ដូច្នេះហើយទើប JICA បានផ្តល់កម្ចីសម្បទានសម្រាប់គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែក្រុងព្រះសីហនុ (ទំហំ ៣.៦៥១លានយ៉េន) ព្រមទាំងបានផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេស ដល់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីចូលរួមចំណែកដល់ការជម្រុញវិនិយោគផ្ទាល់ពីបរទេស។

បច្ចុប្បន្ននេះJICAកំពុងធ្វើការក្នុងភាពជាដៃគូជាមួយនឹងស្ថាប័នអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈជាច្រើនរួមទាំងស្ថាប័នអប់រំដ៏សំខាន់ពីរផ្សេងទៀត គឺវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន ដើម្បីបង្កើនធនធានមនុស្ស និងការអភិវឌ្ឍជំនាញវិជ្ជាជីវៈ។ គោលបំណងចម្បងនៃកិច្ចសហប្រតិបត្តិការនេះគឺដើម្បីកសាងនូវជំនាញទាំងផ្នែកធុរៈកិច្ច និងបច្ចេកទេសដែលជាតម្រូវការចាំបាច់នៅកម្ពុជានាពេលបច្ចុប្បន្ននេះ។ ដូច្នេះហើយទើបកម្មវិធីផ្តល់ជំនួយរបស់ JICA សម្រាប់ការអភិវឌ្ឍធនធានមនុស្សនៅក្នុងវិស័យឧស្សាហកម្ម មានគោលបំណងផ្គត់ផ្គង់ទីផ្សារការងារនូវបុគ្គលដែលមានជំនាញបច្ចេកទេសខ្ពស់ និងសមត្ថភាពមូលដ្ឋានដែលវិស័យឧស្សាហកម្មត្រូវការ។ កម្មវិធីនេះរាប់បញ្ចូលទាំងការគាំទ្រដល់ភ្នាក់ងារមុខរបរជាតិដែលផ្សព្វផ្សាយព័ត៌មានអំពីកម្លាំងពលកម្ម ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

ដោយសារតែសហគ្រាសធុនតូច និងមធ្យមបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យសេដ្ឋកិច្ចកម្ពុជា JICA ក៏បានគាំទ្រដល់ការបង្កើតក្របខណ្ឌនយោបាយលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម និងការពង្រឹងតួនាទីរបស់មជ្ឈមណ្ឌលផលិតភាពជាតិនៃកម្ពុជាសម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមតាមរយៈគម្រោងសម្រាប់ពង្រឹងជាយុទ្ធសាស្ត្រនូវប្រព័ន្ធគាំទ្រសហគ្រាសធុនតូចនិងមធ្យម (កិច្ចសហប្រតិបត្តិការបច្ចេកទេស)។

# កសិកម្ម និងការអភិវឌ្ឍជនបទ

**ប្រលាយទឹកប្រវែងប្រមាណ ១៤៥គីឡូម៉ែត**
ត្រូវបានសាងសង់ដោយប្រើប្រាស់ហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុន (២០០២-២០១៤)

**កំណើនជាង ៦០%**
នៃផលិតផលជំនាំស្រូវរបស់កសិករ ត្រូវបានសម្រេចបានដោយជំនួយបច្ចេកទេសរបស់ JICA

* ពី ២,៧៥តោនក្នុង១ហិចតា (ឆ្នាំ២០១០) ទៅ ៤,៥តោនក្នុង១ហិចតា(ឆ្នាំ២០១៤)

វិស័យកសិកម្មបានចូលរួមចំណែក ២៨,៧ភាគរយ ក្នុងផលិតផលជាតិសរុប និង៥០ភាគរយ ក្នុងកម្លាំងពលកម្មសរុប។ វិស័យនេះ នៅតែមានតួនាទីយ៉ាងសំខាន់ នៅក្នុងការកាត់បន្ថយភាពក្រីក្រ ហើយក៏ជាមូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ចរយៈពេលវែងរបស់ប្រទេសកម្ពុជាផងដែរ។ ទោះបីជាយ៉ាងនេះក្តី វិស័យនេះនៅជួបប្រទះការប្រឈមជាច្រើនដូចជាកង្វះខាតសមត្ថភាពនៅក្នុងប្រព័ន្ធស្រោចស្រព និងការគ្រប់គ្រងធនធានទឹក ព្រមទាំងបច្ចេកទេសនិងចំណេះដឹងផ្នែកផលិតកម្ម និងការកែច្នៃនៅមានកម្រិតនៅឡើយ ដែលជាបញ្ហាបណ្តាលឲ្យកសិករទទួលបានប្រាក់ចំនេញទាប។


មន្ត្រីសមភាគីផ្នែកជលសាស្ត្រ & ជំនាញការ JICA របស់គម្រោង RBWRU កំពុងដំឡើងក្តារម៉ែត្រវាស់ទឹក

ក្នុងការជម្រុញការអភិវឌ្ឍវិស័យកសិកម្ម និងលើកកម្ពស់ជីវភាពរស់នៅរបស់កសិករ JICA បានប្រើប្រាស់យុទ្ធសាស្រ្តស៊ីជម្រៅ ក្នុងការផ្តល់ជំនួយដោយអនុវត្តវិធានការផ្តល់ជំនួយទាំងរយៈពេលខ្លីក៏ដូចជារយៈពេលវែង នៅក្នុងបែបផែនគ្រប់យ៉ាងដែលខ្លួនមាន។

ដើម្បីស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រពដែលមិនដំណើរការ និងខូចខាត JICA បានផ្តល់ជំនួយតាមរយៈការកសាងសមត្ថភាព និងការសាងសង់ប្រព័ន្ធស្រោចស្រពចាប់តាំងពីឆ្នាំ២០០១។ ទាំងនេះគឺបានចាប់ផ្តើមជាមួយនឹង គម្រោងមជ្ឈមណ្ឌលសេវាកម្មបច្ចេកទេសសម្រាប់ប្រព័ន្ធធារាសាស្រ្ត *(ដំណាក់កាលទី១ ដល់ទី៣)* ក្រោមកិច្ចសហប្រតិបត្តិការបច្ចេកទេស ហើយថ្មីៗនេះកំពុងដំណើរការ គម្រោងស្តារឡើងវិញនូវប្រព័ន្ធស្រោចស្រព និងប្រព័ន្ធរំដោះទឹកនៅតំបន់ភាគខាងលិចទន្លេសាប (កម្ចីសម្បទាន ចំនួនទឹកប្រាក់ ៤.២៦៩លាន យ៉េន ប្រមាណជា ៤៣,៧លានដុល្លារសហរដ្ឋអាមេរិក) និងគម្រោងកែលម្អស្តារឡើងវិញនូវប្រព័ន្ធធារាសាស្រ្ត និងរំដោះទឹកភាគនិរតី នៃរាជធានីភ្នំពេញ (កម្ចីសម្បទានចំនួនទឹកប្រាក់ ៥.៦០៦លាន យ៉េន)។ លើសពីនេះ JICA បានផ្តួចផ្តើម គម្រោងស្តីពីការប្រើប្រាស់ធនធានទឹកនៅក្នុងអាងទន្លេនៅក្នុងប្រទេសកម្ពុជា (កិច្ចសហប្រតិបត្តិការបច្ចេកទេស) ក្នុងឆ្នាំ២០១៣ ដើម្បីប្រើប្រាស់ និងដំណើរការប្រព័ន្ធស្រោចស្រពនៅតាមអាងទន្លេនីមួយៗឲ្យមានប្រសិទ្ធភាព។

JICA ក៏បានផ្តល់ជំនួយដល់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈគម្រោងកិច្ចសហការប្រតិបត្តិការបច្ចេកទេសនានាដើម្បីជម្រុញផលិតភាពកសិកម្ម និងបង្កើនសមត្ថភាពរកប្រាក់ចំណូលរបស់កសិករ។ គោលបំណងនៃកិច្ចសហការទាំងនេះត្រូវបានសម្រេចបានតាមរយៈ គម្រោងលើកកម្ពស់ផលិតភាពកសិកម្មនៅខាងលិចទន្លេសាប (កិច្ចសហប្រតិបត្តិការបច្ចេកទេស) និង គម្រោងអភិវឌ្ឍន៍និងផ្សព្វផ្សាយវារីវប្បកម្មទឹកសាប (ជំហានទី១ និងទី២) នៅក្នុងវិស័យជលផល។ ជាងនេះទៅទៀត គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៤ ដើម្បីពង្រឹងសមត្ថភាពរបស់មន្ត្រីរាជការដែលពាក់ព័ន្ធនឹងការងារទ្រទ្រង់និងពង្រឹងក្រុមកសិករ។ ដើម្បីឆ្លើយតបនឹងការអភិវឌ្ឍនិងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងវិស័យកសិកម្ម JICA មិនត្រឹមតែផ្តោតទៅលើការបង្កើនផលិតភាពកសិកម្មប៉ុណ្ណោះទេ ថែមទាំងផ្តោតលើការពង្រឹងគុណភាព ប្រសិទ្ធិភាព ចំណេះដឹង និងចំណេះធ្វើរបស់មន្ត្រីរាជការផងដែរ។



សមាជិកសហគមន៍កសិករ និងមន្ត្រីក្រសួងកសិកម្មកំពុងធ្វើទស្សនៈកិច្ចនៅផ្សារទំនើប AEON ដើម្បីស្វែងយល់ពីការធ្វើទីផ្សារផលិតផលកសិកម្មក្រោមគម្រោងBPAC

## ហិរញ្ញប្បទានរបស់ជប៉ុនក្នុងការកែលម្អប្រព័ន្ធប្រឡាយ-លូនិងប្រព័ន្ធការពារទឹកជំនន់ក្នុងរាជធានីភ្នំពេញ

រាជធានីភ្នំពេញ និងតំបន់ទីប្រជុំជននានាក្នុងប្រទេសកម្ពុជាក៏ដូចជាទីក្រុងផ្សេងៗនៅអាស៊ីអាគ្នេយ៍តែងតែរងគ្រោះដោយទឹកជំនន់និងបញ្ហាប្រព័ន្ធប្រឡាយ–លូ ដោយសារទឹកភ្លៀង។ នៅប្រទេសកម្ពុជាដោយសារ ប្រជាជនភាគច្រើនរស់នៅប្រមូលផ្តុំគ្នានៅតាមតំបន់ទំនាប ជាហេតុនាំអោយសហគមន៍ ទាំងនោះងាយរងគ្រោះដោយសារទឹកជំនន់។ ដូចនេះរាជរដ្ឋាភិបាលត្រូវតែមានវិធានការចាំបាច់ដើម្បីដោះស្រាយបញ្ហានេះ។




ក្នុងស្ថានភាពដូច្នេះ JICA បានផ្តល់អាទិភាពខ្ពស់ក្នុងការធ្វើអោយប្រសើរឡើងនូវការការពារទឹកជំនន់ និងប្រព័ន្ធប្រឡាយ–លូ ដើម្បីធានា និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជននៅតំបន់ទីប្រជុំជន។ ស្ថិតក្នុងក្របខណ្ឌនេះ JICA បាន និងកំពុងជួយដល់រាជធានីភ្នំពេញ និងទីក្រុងនានាចាប់តាំងពីឆ្នាំ១៩៩៩មកម្ល៉េះ។ មកទល់ពេលនេះ JICA បានផ្តល់នូវគម្រោងកែលម្អច្រាំងទន្លេ គម្រោងសាងសង់ស្ថានីយ៍បូមទឹក គម្រោងស្តារប្រព័ន្ធឡាយ–លូឡើងវិញ គម្រោងដាក់បំពង់លូរធំៗ ព្រមទាំងប្រព័ន្ធចម្រោះ។ គម្រោងទាំងនេះបានចូលរួមចំណែកក្នុងការកាត់បន្ថយផលប៉ះពាល់ ពីទឹកភ្លៀង និងកាត់បន្ថយជាអតិបរិមានូវកម្រិតនៃជំនន់ទឹកភ្លៀង និងរយៈពេលនៃទឹកជំនន់ក្នុងតំបន់ប្រជុំជន។

បច្ចុប្បន្ន JICA បាននឹងកំពុងសហការជាមួយសាលារាជធានីភ្នំពេញ ក្នុងការកសាងប្លង់មេដែលមានរយៈពេល២០ឆ្នាំចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០៣៥ ដើម្បីកំណត់បន្ថែមទៀតអំពីអាទិភាពចាំបាច់សម្រាប់ការកែលម្អប្រព័ន្ធប្រឡាយ–លូ ដោយរួមបញ្ចូលផងដែរនូវការពិចារណាលើការអភិវឌ្ឍនូវប្រព័ន្ធបង្ហូរទឹកកង្វក់ឲ្យមានប្រសិទ្ធភាពនៅក្នុងរាជធានីភ្នំពេញ។

ការសិក្សាលើគម្រោងកែលម្អប្រព័ន្ធប្រឡាយ–លូ នៅក្នុងរាជធានីភ្នំពេញ ៖ (គម្រោងសហប្រតិបត្តិការបច្ចេកទេស ២០១៤-២០១៦។
គម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយ–លូនៅក្នុងរាជធានីភ្នំពេញ(ជំហ៊ានទី៣) ៖ ហិរញ្ញប្បទានឥតសំណង(២០១១-២០១៥)
គម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយ–លូ នៅក្នុងរាជធានីភ្នំពេញ(ជំហ៊ានទី២) ៖ ហិរញ្ញទានឥតសំណង(២០០៧-២០១០)
គម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយ–លូ នៅក្នុងរាជធានីភ្នំពេញ ៖ (ហិរញ្ញទានឥតសំណង) (២០០១- ២០០៤)
ការសិក្សាលើគម្រោងកែលម្អប្រព័ន្ធប្រឡាយ–លូ និងការគ្រប់គ្រងទឹកជំនន់នៅក្នុងរាជធានីភ្នំពេញ ៖ (គម្រោងសហប្រតិបត្តិការបច្ចេកទេស ១៩៩៨-១៩៩៩)។

### វិស័យអាទិភាពទី២

# ការលើកកម្ពស់ការអភិវឌ្ឍសង្គម

កំណើនសេដ្ឋកិច្ចពុំមែនជានិច្ចជាកាលនាំមកនូវការអភិវឌ្ឍសង្គមប្រកបដោយសមធម៌មួយដោយសមាជិកទាំងអស់នៃសង្គមនោះទទួលបានផលប្រយោជន៍ដូចគ្នានោះទេ។ ដូច្នេះនៅក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ចគេត្រូវតែយកចិត្តទុកដាក់លើការផ្តល់ និងការកែលម្អឡើងវិញនូវសេវាមូលដ្ឋាន ដូចជា ការមានទឹកស្អាតប្រើប្រាស់ សេវាថែទាំសុខភាព និងការអប់រំ ដែលសុទ្ធតែជាសេវាចាំបាច់សម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស។ ការកែសម្អសេវាទាំងអស់នេះមានចែងនៅក្នុងគោលដៅអភិវឌ្ឍសហស្សវត្សរ៍របស់កម្ពុជា (Cambodia's MDGs) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព (SDGs)។ កម្រិតជីវភាពរបស់ប្រជាជនកម្ពុជាមានការប្រសើរឡើង តាមរយៈកំណើននៃអត្រាប្រជាជនទទួលបានទឹកស្អាតប្រើប្រាស់ ទទួលបានសេវាថែទាំសុខភាព និងការអប់រំ ដោយសារកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ក្នុងនោះមាន JICA និងអង្គការសង្គមស៊ីវិលនានា ក្នុងរយៈពេល ២០ឆ្នាំចុងក្រោយនេះ។ ទោះជាដូច្នេះក្តី កង្វះខាតដែលត្រូវបំពេញបន្ថែមទៀតនៅតែមាននៅក្នុងដំណាក់កាលនៃការអភិវឌ្ឍបច្ចុប្បន្នដែលតម្រូវអោយគេត្រូវផ្តល់ការយកចិត្តទុកដាក់បន្ថែមទៀតទៅលើកត្តាគុណភាព និងបរិមាណដែលគេត្រូវការសម្រាប់ការអភិវឌ្ឍសង្គម។

## ការផ្គត់ផ្គង់ទឹកស្អាតនិងប្រព័ន្ធប្រឡាយ-លូទឹកស្អុយ

**ប្រជាជនចំនួន**

**១ ១០០ ០០០នាក់**

ទទួលសេវាទឹកស្អាត
តួលេខសរុបរួមទាំងអតិថិជន
នៅក្នុងគម្រោងថ្មីផងដែរ

ប្រព័ន្ធទឹកស្អាតនៅកម្ពុជា ទទួលរងការបំផ្លាញស្ទើរតែទាំងស្រុងនៅក្នុងរបបប៉ុល ពត។ មុនទសវត្សទី៩០ ប្រជាជនកម្ពុជាជួបការលំបាកក្នុងការទទួលបានទឹកស្អាតប្រើប្រាស់ ក្នុងខណៈពេលដែលការចែកចាយទឹកស្អាតដោយឯកជនមិនមានគុណភាពល្អ និងមានតម្លៃខ្ពស់។ JICA បានចាប់ផ្តើមសហការជាមួយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញក្នុងឆ្នាំ១៩៩៣ និងបានសិក្សាអំពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅរាជធានីភ្នំពេញ (គម្រោងសហប្រតិបត្តិការបច្ចេកទេស) ដែលក្រោយមកត្រូវបានគេសិក្សាបន្ថែមក្លាយជាផែនការមេប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរាជធានីភ្នំពេញក្នុងឆ្នាំ២០០៦ (ដំណាក់កាលទី២) (កិច្ចសហប្រតិបត្តិការបច្ចេកទេស)។ ផ្តើមចេញពីលទ្ធផលនៃផែនការមេ JICA បានបន្តផ្តល់ជំនួយជាច្រើន ដើម្បីគាំទ្រយុទ្ធសាស្ត្រខាងក្រោម ហើយបានប្រែក្លាយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញជាស្ថាប័នមួយដែលជោគជ័យជាងគេ និងមានស្នាដៃល្អក្នុងចំណោមរដ្ឋាករសាធារណៈទាំងអស់ទូទាំងពិភពលោក។

១. ប្រើប្រាស់ហិរញ្ញប្បទានឥតសំណង សម្រាប់ការស្តារឡើងវិញ សម្រាប់សាងសង់ និងសម្រាប់ផ្លាស់ប្តូរ/ពង្រីកបណ្តាញទុយយោទឹកជាបន្ទាន់

២. សហប្រតិបត្តិការបច្ចេកទេស តាមរយៈគម្រោងពង្រឹងសមត្ថភាពបុគ្គលសម្រាប់ការគ្រប់គ្រងប្រតិបត្តិការ និងការថែទាំបរិក្ខារទឹកស្អាតប្រកបដោយប្រសិទ្ធភាព។

៣. ផ្តល់កម្ចីសម្បទានសម្រាប់ពង្រឹងសម្ថភាពរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញបន្ថែមដើម្បីគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដែលមានសុវត្ថិភាព និងតម្លៃសមរម្យ។

សរុបហិរញ្ញប្បទានទាំងអស់របស់ជប៉ុនដល់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញមានចំនួនប្រហែល ១២៤ លានដុល្លាសហរដ្ឋអាមេរិកគិតត្រឹមឆ្នាំ២០១៣(តួលេខរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ)។

ក្រៅពីរាជធានីភ្នំពេញ JICA បានកំពុងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ខ្លួនដើម្បីកែលម្អការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងបណ្តាខេត្តផ្សេងៗចាប់តាំងពីឆ្នាំ២០០៦មកតាមរយៈ (១) គម្រោងសហប្រតិបត្តិការបច្ចេកទេសដោយសហការជាមួយរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដើម្បីពង្រឹងសមត្ថភាពបច្ចេកទេសនិងសមត្ថភាពគ្រប់គ្រងដល់រដ្ឋាករទឹកតាមខេត្តគោលដៅចំនួន ៨ រួមមាន៖ ពោធិសាត់ បាត់ដំបង សៀមរាប កំពង់ធំ កំពង់ចាម ស្វាយរៀង កំពត និងខេត្តព្រះសីហនុ (២) ហិរញ្ញប្បទានឥតសំណង និងកម្ចីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ សម្រាប់សាងសង់បរិក្ខារផ្គត់ផ្គង់ទឹកស្អាត មានដូចជា រោងចក្រប្រតិកម្មទឹកស្អាត និងសម្រាប់ផ្លាស់ប្តូរ និងពង្រីកបណ្តាញទុយយោទឹកនៅក្នុងក្រុងសំខាន់ៗ។ ផ្អែកតាមស្ថិតិរបស់ក្រសួងឧស្សាហកម្មនិងសិប្បកម្មប្រជាជននៅតាមទីក្រុងនិងទីប្រជុំជនដែលទទួលបានទឹកស្អាតប្រើប្រាស់បានកើនឡើងយ៉ាងខ្លាំងពី៥៣,៥% នៅក្នុងឆ្នាំ២០០៩ ដល់ ៨១,២៨% នៅក្នុងឆ្នាំ២០១៤។ ទោះជាយ៉ាងណាក៏ដោយ ក្រៅពីទីក្រុងភ្នំពេញដែលមានប្រជាជនអាចទទួលបានទឹកស្អាតប្រើប្រាស់ប្រមាណ៩០%ការទទួលបានទឹកស្អាតប្រើប្រាស់នៅតាមបណ្តាខេត្ត ក្រុងនានានៅមានកំរិតទាបនៅឡើយ (៦៥,៧១%) តួលេខនេះស្ថិតនៅឆ្ងាយពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាដែលតម្រូវសម្រេចឲ្យបាន៨០%ត្រឹមឆ្នាំ២០១៥។ ក្នុងការជួយឲ្យប្រសើរឡើងបន្ថែមទៀត JICA កំពុងបន្តការគាំទ្រលើការសាងសង់បរិក្ខារ និងកែលម្អប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅក្នុងក្រុងសំខាន់ៗបន្ថែមទៀត ដោយប្រើប្រាស់ចំណេះដឹង និងបទពិសោធន៍ដែលជោគជ័យទាំងឡាយនៅកម្ពុជា។



*បុគ្គលិករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញកំពុងតបណ្តាញទឹកចូលផ្ទះ (ថតរូបដោយ លោក គែនស៊ី អ៊ីម៉ាមូរ៉ា)*



*សកម្មភាពសាងសង់ប្រព័ន្ធប្រឡាយ-លូនៅក្នុងរាជធានីភ្នំពេញ*



*ចាប់តាំងពីឆ្នាំ១៩៩៦មក JICA ក៏បានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងដើម្បីផ្តល់សេវាទឹកស្អាតដល់ប្រជាពលរដ្ឋនៅជនបទតាមរយៈការសាងសង់អណ្តូងស្នប់ចំនួន៦៥៥អណ្តូងនៅតំបន់ជាយទីក្រុងភ្នំពេញនិងក្នុងខេត្តកំពង់ចាម ។*

# សុខភាព និងការថែទាំវេជ្ជសាស្ត្រ

**ទារកច្រើនជាង**

**១១០ ០០០នាក់**

បានប្រសូតក្នុងមជ្ឈមណ្ឌលជាតិគាំពារ សុខភាពមាតា និងទារក ចន្លោះឆ្នាំ ១៩៩៧-២០១៤

នៅដើមទសវត្សទី ៩០ ប្រព័ន្ធសុខាភិបាលនៅកម្ពុជា ប្រឈមនឹងការខូចខាត យ៉ាងធ្ងន់ធ្ងរទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស។ ការស្តារឡើងវិញនូវភាពខ្វះចខ្វាំទាំងនេះ ជាការចាំបាច់បំផុតដើម្បីជួយសង្គ្រោះជីវិតរបស់ប្រជាជនកម្ពុជា បន្ទាប់ពីរបបប៉ុល ពត។ ដោយមើលឃើញពីការលំបាកទាំងអស់នេះ JICA បានចាប់ផ្តើមគាំទ្រដល់ការស្តារ និង កសាងហេដ្ឋារចនាសម្ព័ន្ធមន្ទីរពេទ្យ ជាបន្ទាន់ តាមរយៈហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណង ដូចជា គម្រោងសាងសង់មជ្ឈមណ្ឌលជាតិគាំពារសុខភាពមាតានិងទារក (ហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងមានចំនួន ១.៧៦១លានយ៉េន ប្រមាណជា ១៨លានដុល្លារសហរដ្ឋអាមេរិក) គម្រោងកែលម្អមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺរបេងនិងហង់សិន (ហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណង មានចំនួន ៨០៣ លានយ៉េន ស្មើនឹងប្រមាណ ៨,២៣ លានដុល្លារសហរដ្ឋអាមេរិក) និង គម្រោងកែលម្អឡើងវិញមន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម (ហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណងមាន ចំនួន ១.០៣៩ លានយ៉េន ស្មើនឹងប្រមាណ ១០,៦៥ លានដុល្លារសហរដ្ឋអាមេរិក)។ បន្ថែមលើការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការបន្ទាន់ JICA ក៏បានចូលរួមក្នុងការអភិវឌ្ឍធនធានមនុស្សផ្នែកសុខភាពមាតានិងទារក និងការគ្រប់គ្រងជម្ងឺរបេងផងដែរ ។



ស្ត្រីកំពុងសម្រាលកូននៅមូលដ្ឋានសុខាភិបាល

ចាប់តាំងពីឆ្នាំ១៩៩២ មក JICAបានសហការយ៉ាងសកម្មជាមួយ មជ្ឈមណ្ឌលជាតិគាំពារសុខភាពមាតានិងទារក តាមរយៈកិច្ចសហប្រតិបត្តិការបច្ចេកទេស ដូចជា គម្រោងគាំពារសុខភាពមាតានិងទារក (ជំហ៊ានទី១ និងទី២) គម្រោងពង្រឹងសេវាកម្មសុខភាពមាតានិងទារក និង គម្រោងថែទាំសុខភាពមាតានិងទារកតាមរយៈការអភិវឌ្ឍសមត្ថភាពឆ្មប។ ជាមួយនឹងការខិតខំប្រឹងប្រែងទាំងនេះសូចនាករនានាក្នុងវិស័យសុខាភិបាល ដូចជា អត្រាមរណៈភាពមាតានិងទារក បានថយចុះគួរឲ្យកត់សំគាល់ក្នុងឆ្នាំ២០១០។ បន្ទាប់ពីមានសហប្រតិបត្តិការ អស់រយៈពេលជាច្រើនឆ្នាំមកបច្ចុប្បន្នមជ្ឈមណ្ឌលជាតិគាំពារសុខភាពមាតានិងទារក មានសមត្ថភាពអាចផ្តល់កិច្ចសហប្រតិបត្តិការជាមួយប្រទេសផ្សេងទៀតដូចជាប្រទេសអាហ្វហ្គានីស្ថាន។

កម្ពុជាមានអត្រាឆ្លងជម្ងឺរបេងខ្ពស់ជាងគេនៅលើពិភពលោក នៅក្នុងទសវត្សទី ៩០។ ប្រឈមនឹងស្ថានភាពប្រកាសអាសន្ន រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងមជ្ឈមណ្ឌលជម្ងឺរបេង និងបានចាប់ផ្តើមកម្មវិធី DOTs ជាមួយនឹងការសហការពីអង្គការសុខភាពពិភពលោកផងដែរ។ JICA បានចាប់ផ្តើមពីការបញ្ជូនទីប្រឹក្សាម្នាក់ នៅក្នុងឆ្នាំ ១៩៩៧ និងបានធ្វើការអស់រយៈពេលជាង១០ឆ្នាំកន្លងមកហើយ ជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺរបេង និងហង់សិនក្នុងការកែលម្អគុណភាព និងទំហំកម្មវិធី DOTs តាមរយៈគម្រោងគាំទ្រប្រយុទ្ធប្រឆាំងជម្ងឺរបេង (ជំហ៊ានទី១ និងទី២) (គម្រោងសហប្រតិបត្តិការបច្ចេកទេស)។ ការអង្កេតថ្នាក់ជាតិលើអត្រារាលដាលជម្ងឺរបេងដើម្បីត្រួតពិនិត្យពីប្រសិទ្ធភាពរបស់កម្មវិធី DOTs ត្រូវបានធ្វើឡើងដោយមានការគាំទ្រពី JICA ហើយតាមរយៈលទ្ធផលដែលទទួលបានពីការអង្កេតនេះ ការអនុវត្តន៍កម្មវិធី DOTs នៅកម្ពុជាត្រូវបានពិភពលោកកោតសរសើរយ៉ាងខ្លាំង ថាជាគំរូអនុវត្តល្អនៅក្នុងការកំចាត់រោគរបេង។

* ពាក្យកាត់របស់ Direct Observed Treatment, Short-course.

## កិច្ចសហប្រតិបត្តិការក្នុងចំនោមប្រទេសកំពុងអភិវឌ្ឍន៍

ក្នុងបរិបទនៃការអភិវឌ្ឍបច្ចុប្បន្ន កិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍន៍ដូចគ្នាកំពុងទទួលបានការចាប់អារម្មណ៍ថាជាការសហការមួយបន្ថែមលើកិច្ចសហប្រតិបត្តិការរវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍។ កិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងអភិវឌ្ឍន៍គឺជាដំណើរការមួយដែលប្រទេសកំពុងអភិវឌ្ឍន៍ដូចគ្នា ចូលរួមចែករំលែកចំណេះដឹង ជំនាញធនធាន និងបច្ចេកទេស ដើម្បីសម្រេចបាននូវគោលដៅជាក់លាក់របស់ខ្លួន ឬគោលដៅរួមគ្នាក្នុងការកសាងសមត្ថភាព។ JICA បានចូលរួមយ៉ាងសកម្មក្នុងការជម្រុញយន្តការនេះក្នុងតួនាទីជាអ្នកនាំមុខគេនៅលើពិភពលោក។



មន្ត្រីដោះមីនពីប្រទេស Angola រៀនពីការអនុវត្តផ្ទាល់នៅចំការមីន

នៅប្រទេសកម្ពុជា គេឃើញមានកិច្ចសហប្រតិបត្តិការរបៀបនេះកើតមាននៅក្នុង វិស័យបោសសម្អាតមីន និងវិស័យសេវាទឹកស្អាត។ JICA បានជួយដល់វិស័យបោសសម្អាតមីននៅកម្ពុជាតាមរយៈការសហការជាមួយនឹងមជ្ឈមណ្ឌលបោសសម្អាតមីនកម្ពុជាចាប់តាំងពីទសវត្សទី៩០។ ក្នុងកិច្ចសហការដែលមានរយៈពេលយូរអង្វែងនេះ សមត្ថភាពរបស់មជ្ឈមណ្ឌលបោសសម្អាតមីនកម្ពុជាត្រូវបានពង្រឹងជាបន្តបន្ទាប់រហូតទទួលបានកេរ្តិ៍ឈ្មោះលើឆាកអន្តរជាតិថាជាអង្គភាពបោសសម្អាតមីនដែលនាំមុខគេ។ បច្ចុប្បន្នមជ្ឈមណ្ឌលនេះធ្វើទាំងការងារបោសសម្អាតមីននៅកម្ពុជា ទាំងការងារផ្សព្វផ្សាយចំណេះដឹង បទពិសោធន៍និងជំនាញរបស់ខ្លួន ដល់ប្រទេសដទៃទៀតដែលជួបបញ្ហាមីនដូចកម្ពុជាដែរ។ រហូតមកទល់ឆ្នាំ២០១៤ មជ្ឈមណ្ឌលបានធ្វើកិច្ចសហការរវាងប្រទេសកំពុងអភិវឌ្ឍន៍នេះជាមួយប្រទេសដៃគូមានដូចជា កូឡុំប៊ី ឡាវ និងអង់ហ្គោឡា បានយ៉ាងជោគជ័យជាមួយនឹងការសម្របសម្រួល និងគាំទ្រពីJICA។

វិស័យទឹកស្អាតនៅកម្ពុជាជាវិស័យមួយដែលគេទទួលស្គាល់ជាអន្តរជាតិ។ ប្រទេសជាច្រើនចង់សិក្សា និងផ្លាស់ប្តូរបទពិសោធន៍ជាមួយនឹងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងរដ្ឋាករទឹកស្វយ័តខេត្តសៀមរាប។ JICA បានជួយប្រទេសជាច្រើននៅក្នុងគម្រោងផ្គត់ផ្គង់ទឹកស្អាត ហើយបានជ្រើសរើសប្រទេសកម្ពុជា ជាកន្លែងបណ្តុះបណ្តាលលើវិស័យផ្គត់ផ្គង់ទឹកស្អាត។ មកទល់ពេលនេះមានកម្មវិធីបណ្តុះបណ្តាលមួយចំនួនបានធ្វើឡើងសម្រាប់មន្ត្រីមកពីប្រទេស ភូមា នេប៉ាល់ ឡាវ ទីម័រ និងនេហ្សេរីយ៉ា។ ដោយសារទទួលបានការវាយតម្លៃខ្ពស់ពីសិក្ខាកាមដែលមកពីប្រទេសទាំងនេះ បុគ្គលិករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានបន្តផ្តល់ការបណ្តុះបណ្តាលដល់ក្រុមសិក្ខាកាមមកពីបណ្តាប្រទេសផ្សេងៗ ដែលសិក្សាក្នុងប្រទេសជប៉ុនតាមរយៈការប្រជុំដោយផ្ទាល់តាមទូរទស្សន៍។

តាមរយៈសកម្មភាពនេះ JICA សង្ឃឹមថានឹងអាចផ្ទេរបទពិសោធន៍សម្រាប់ជាគុណប្រយោជន៍ទៅដល់ប្រជាជនមកពីកន្លែងផ្សេងគ្នាលើពិភពលោក ព្រមទាំងសង្ឃឹមថាអាចជួយជំរុញបន្ថែមនូវកិច្ចសហប្រតិត្តិការជាមួយប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត។

## សិស្សានុសិស្សច្រើនជាង ៦០ ០០០នាក់ នៅភ្នំពេញ

### បានសិក្សានៅសាលាបឋមសិក្សាចំនួន១៨ ដែលសាងសង់តាមរយៈហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុន (២០០៤-២០១៤)

ប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជា ត្រូវបានបំផ្លិចបំផ្លាញស្ទើរគ្មានសល់ក្នុងរបប ប៉ុល ពត។ ចាប់តាំងពីទសវត្សទី៩០ ទោះបីជារាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងស្តារប្រព័ន្ធអប់រំឡើងវិញ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍នានា ដូចជា JICA និងអង្គការក្រៅរដ្ឋាភិបាលក៏ដោយ ក៏ប្រព័ន្ធអប់រំនេះ នៅតែជួបប្រទះបញ្ហាប្រឈមនានា ដូចជា អត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ និងកង្វះគ្រូដែលមានសមត្ថភាព ដែលជះឥទ្ធិពលដោយផ្ទាល់ទៅលើ គុណភាពអប់រំ និងសក្តានុពលបញ្ញារបស់កុមារ។



*សិស្សរៀននៅក្នុងសាលាមួយ ដែលសាងសង់ដោយការគាំទ្ររបស់ប្រទេសជប៉ុន*

ដោយសារប្រទេសជប៉ុនមានធនធានមនុស្សប្រកបដោយវិជ្ជាជីវៈ ក្នុងជំនាញវិទ្យាសាស្រ្ត និងគណិតវិទ្យា JICA បានចាប់ផ្តើមអនុវត្ត គម្រោងបណ្តុះបណ្តាលគ្រូមធ្យមសិក្សាលើមុខវិជ្ជាវិទ្យាសាស្រ្ត និងគណិតវិទ្យានៅកម្ពុជា (ជំហ៊ាន ទី១ និងទី២) (គម្រោងសហប្រតិបត្តិការបច្ចេកទេស) ចាប់តាំងពីឆ្នាំ២០០០ រហូតដល់ឆ្នាំ២០១២។ គម្រោងនេះមានគោលបំណងពង្រឹងសមត្ថភាពរបស់វិទ្យាស្ថានជាតិអប់រំ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូថ្នាក់ខេត្ត និងតំបន់ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀនផ្នែកវិទ្យាសាស្រ្ត និងគណិតវិទ្យា។ បច្ចុប្បន្ន JICA កំពុងអនុវត្ត គម្រោងអភិវឌ្ឍធនធានសម្រាប់ការអប់រំមុខ វិជ្ជាវិទ្យាសាស្រ្ត និងគណិតវិទ្យា នៅកម្រិតមធ្យមសិក្សាបឋមភូមិ (គម្រោងសហប្រតិបត្តិការបច្ចេកទេស) ដែលមានបំណងពង្រឹងមូលដ្ឋានគ្រឹះរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីគាំទ្រដល់គ្រូនៅក្នុងការពង្រឹងជំនាញបង្រៀនផ្នែកវិទ្យាសាស្រ្ត និងគណិតវិទ្យារបស់ខ្លួន។



*សកម្មភាពនៃគម្រោងការអប់រំគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្រ្ត*

លើសពីនេះដើម្បីឆ្លើយតបនឹងកង្វះខាតអគារសិក្សា JICA បានផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់គម្រោងសាងសង់សាលាបឋមសិក្សានៅក្នុងរាជធានីភ្នំពេញ (ដំណាក់កាលទី១ ទី២ និងទី៣) (ហិរញ្ញប្បទានឥតសំណងមាន ចំនួន១.៥៤៣លានយ៉េន ស្មើនឹង ១៥,៨ លានដុល្លារសហរដ្ឋអាមេរិក) ដើម្បីកែលម្អបរិយាកាសសម្រាប់ការសិក្សារបស់សិស្ស។

JICA គិតគូរដល់ការកែលម្អប្រព័ន្ធអប់រំជាអាទិភាពខ្ពស់ ពីព្រោះនៅក្នុងវិស័យឧស្សាហកម្មនឹងមានតម្រូវការធនធានមនុស្សដែលមានជំនាញខ្ពស់ជាច្រើន។ JICA នឹងបន្តគាំទ្រដល់ការកែលម្អគុណភាពអប់រំ ផ្នែកវិទ្យាសាស្រ្ត និងគណិតវិទ្យា ដើម្បីឲ្យកុមារទាំងឡាយមានភាពរីករាយក្នុងការសិក្សាក៏ដូចជាមានការអភិវឌ្ឍជំនាញក្នុងការគិតតាមបែបតក្កវិភាគ និងសមត្ថភាពធ្វើ។ សិស្សដែលមានសមត្ថភាពទាំងនេះនឹងក្លាយជាធនធានមនុស្សដ៏សំខាន់ដែលនឹងចូលរួមស្ថាបនាប្រទេសកម្ពុជាឲ្យមានការអភិវឌ្ឍក្នុងរយៈពេលយូរអង្វែង ។

## ហិរញ្ញប្បទានឥតសំណងអាហារូបករណ៍សម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស

កម្មវិធីបណ្តុះបណ្តាល និងពិភាក្សា ជាទម្រង់មួយនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសដែល JICA ធ្វើនៅប្រទេសជប៉ុន។ កម្មវិធីទាំងពីរនេះផ្តល់ឱកាសដល់សិក្ខាកាមដែលជាដៃគូសហប្រតិបត្តិការរបស់គម្រោងទាំងឡាយ ដែលផ្តល់ហិរញ្ញប្បទានដោយជំនួយអភិវឌ្ឍន៍ផ្លូវការជប៉ុនអោយទទួលបានចំណេះដឹង ជំនាញ បទពិសោធន៍របស់ជប៉ុននៅក្នុងវិស័យជាច្រើន ដែលប្រទេសបញ្ជូនសិក្ខាកាមត្រូវការ។ JICA ទទួលសិក្ខាកាមពីកម្ពុជាក្នុងគោលបំណងបង្កើនធនធានមនុស្ស ដើម្បីចូលរួមដោះស្រាយបញ្ហាអភិវឌ្ឍន៍របស់កម្ពុជា។ រហូតដល់ឆ្នាំ២០១៤ មានសិក្ខាកាមច្រើនជាង១០.០០០នាក់ ត្រូវបានបណ្តុះបណ្តាលនៅប្រទេសជប៉ុនសម្រាប់វិស័យដូចជាអភិបាលកិច្ច កសិកម្មសុខាភិបាល ដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធ ឧស្សាហកម្ម។ល។និង។ល។



*រូបថតជាក្រុមៈ ពិធីជួបជុំមុនចេញដំណើរទៅប្រទេសជប៉ុន*

បន្ថែមលើកម្មវិធីបណ្តុះបណ្តាលខាងលើ JICA បានកំពុងផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់អាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្សសម្រាប់បណ្តុះបណ្តាលមន្ត្រីវ័យក្មេងនៃប្រទេសកំពុងអភិវឌ្ឍន៍។ កម្មវិធីនេះផ្តល់ឱកាសដល់សិក្ខាកាម ក្នុងការក្រេបជញ្ជក់ចំណេះដឹង ជំនាញធ្វើការស្រាវជ្រាវ និងបង្កើតបណ្តាញទំនាក់ទំនងធនធានមនុស្សតាមរយៈកម្មវិធីសិក្សាថ្នាក់អនុបណ្ឌិតនៅសាកលវិទ្យាល័យនានារបស់ជប៉ុន។ នៅប្រទេសកម្ពុជា កម្មវិធីនេះបានចាប់ផ្តើមក្នុងឆ្នាំ២០០០ ហើយមកដល់ឆ្នាំ២០១៤ មានមន្ត្រីរាជការជំនាន់ក្រោយចំនួន៣២០រូប ត្រូវបានបញ្ជូនទៅសិក្សាលើមុខវិជ្ជាជាច្រើននៅប្រទេសជប៉ុន។

កម្មវិធីបណ្តុះបណ្តាលខាងលើនេះ សុទ្ធសឹងតែជាកម្មវិធីសំខាន់ៗនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់អភិវឌ្ឍន៍ធនធានមនុស្ស និងជាការឆ្លើយតបទៅនឹងតម្រូវការនៃដំណោះស្រាយសម្រាប់បញ្ហាអភិវឌ្ឍន៍នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ អតីតសិក្ខាកាមនៃកម្មវិធីបណ្តុះបណ្តាលទាំងនេះបានកំពុងចូលរួមយ៉ាងសកម្មដោះស្រាយបញ្ហាអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។ ដើម្បីជាជំនួយក្នុងការអនុវត្តសកម្មភាពរបស់ពួកគេ សមាគមន៍សិក្ខាកាមកម្ពុជានៃវគ្គបណ្តុះបណ្តាលរបស់ JICA ត្រូវបានបង្កើតឡើងនៅដើមឆ្នាំ២០១២ ដោយមានសមាជិកប្រហែល១ ៧៨០នាក់ ដើម្បីពង្រឹងបណ្តាញទំនាក់ទំនងរបស់សិក្ខាកាមអោយកាន់តែស្អិតរមួតជាងមុននិងពង្រឹងទំនាក់ទំនងនិងមិត្តភាពរវាងសិក្ខាកាមដែលធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុនតាមរយៈ JICA។

## វិស័យអាទិភាពទី ៣

# ការពង្រឹងអភិបាលកិច្ច

អភិបាលកិច្ចល្អជាបុរេលក្ខខណ្ឌមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយចិរភាព និងសមធ៌ម។ រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកអភិបាលកិច្ចល្អជាចំណុចស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់ខ្លួន និងយកចិត្តទុកដាក់លើកំណែទម្រង់មានដូចជា កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ (រួមទាំងវិមជ្ឈការនិងសហវិមជ្ឈការ) និងកំណែទម្រង់ច្បាប់និងតុលាការ។ ទោះជាដូច្នេះក្តី ធនធានមនុស្ស និងសមត្ថភាពស្ថាប័នជាកត្តាដ៏ចាំបាច់ និងកំពុងត្រូវការដើម្បីជម្រុញប្រសិទ្ធភាព និងដំណើរការដោយរលូនស្របគ្នាជាមួយនឹងកំណែទម្រង់ទាំងអស់នេះ។ ជំនួយនៅតែជាសេចក្តីត្រូវការជាមូលដ្ឋាននៅក្នុងកំណែទម្រង់ទាំងនេះ។ ជាងនេះទៅទៀត សមភាពយេនឌ័រក៏ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកជាធាតុដ៏សំខាន់ក្នុងអភិបាលកិច្ចល្អផងដែរ។

## កម្មវិធីពង្រឹងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ស្ថានភាពហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា នៅមិនទាន់មានភាពប្រសើរទាំងស្រុងនៅឡើយទេ។ ជាក់ស្តែងចំណូលពន្ធមានត្រឹមតែ ១៤,៥% នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ២០១៤។ អត្រាចំណូលពន្ធនេះជាអត្រាទាបជាងគេបំផុតនៅក្នុងចំណោមប្រទេសនៅក្នុងតំបន់ទន្លេមេគង្គ។

JICA កំពុងគាំទ្រការកសាងសមត្ថភាពមន្ត្រី និងស្ថាប័ននៅក្នុងវិស័យគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការអភិវឌ្ឍសមត្ថភាពរបស់អគ្គនាយកដ្ឋានពន្ធដា នៅក្រោមក្របខណ្ឌកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (កិច្ចសហប្រតិបត្តិការបច្ចេកទេស)។ គម្រោងនេះផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋានពន្ធដារតាមរយៈការកសាងជំនាញ និងសមត្ថភាពរបស់មន្ត្រីក្នុងការធ្វើការត្រួតពិនិត្យពន្ធ។ បន្ថែមលើនេះទៀត គម្រោងបានពង្រឹងសេវាកម្មបង់ពន្ធ តាមរយៈការលើកកម្ពស់ការយល់ដឹងរបស់អ្នកបង់ពន្ធ និងការប្រមូលពន្ធឲ្យបានត្រឹមត្រូវ និងមានតម្លាភាព។

JICA ក៏បានបញ្ជូនទីប្រឹក្សាផ្នែកគោលនយោបាយនិងគ្រប់គ្រងផ្នែកគយនិងរដ្ឋាករ ដើម្បីជួយធ្វើឲ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករ អាចបោះជំហានឆ្ពោះទៅការគ្រប់គ្រងគយនិងរដ្ឋាករស្របតាមស្តង់ដារអន្តរជាតិ និងធ្វើទំនើបកម្មការគ្រប់គ្រងរបស់អគ្គនាយកដ្ឋាន។ JICA បានកំពុងលើកទឹកចិត្តរាជរដ្ឋាភិបាលកម្ពុជាឲ្យពង្រឹងមូលដ្ឋានចំណូលរបស់ខ្លួន ដើម្បីឲ្យរដ្ឋាភិបាលអាចផ្តល់សេវាកម្មសាធារណៈផ្សេងៗ ដែលចាំបាច់សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។

ក្រាហ្វិក ៤ - ចំណូលក្នុងស្រុក និងភាគរយនៃចំណូលពន្ធធៀបនឹង GDP




*ប្រភព៖ សូចនាករសំខាន់ៗរបស់ធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ២០១៥*

## កម្មវិធីកំណែទម្រង់ប្រព័ន្ធច្បាប់ និងតុលាការ និងកម្មវិធីមុខងាររដ្ឋបាលសាធារណៈ

ចាប់តាំងពីឆ្នាំ១៩៩៩ JICA បានសហការជាមួយ ក្រសួងយុត្តិធម៌ និងស្ថាប័នដទៃទៀតដើម្បីដោះស្រាយការប្រឈមជាច្រើន នៅក្នុងវិស័យច្បាប់និងតុលាការ រួមមានការអភិវឌ្ឍច្បាប់ជាមូលដ្ឋាន និងធនធានមនុស្ស។ JICAបានអនុវត្តគម្រោងការអភិវឌ្ឍប្រព័ន្ធច្បាប់និងតុលាការ (ដំណាក់កាលទី១ដល់ទី៣) (កិច្ចសហប្រតិបតិការបច្ចេកទេស) ដោយមានសហការជាមួយក្រុមសាស្រាចារ្យប្រកបដោយបទពិសោធន៍ខ្ពស់ និងអ្នកអនុវត្តច្បាប់មកពីស្ថាប័នពាក់ព័ន្ធនានានៅប្រទេសជប៉ុន នៅក្នុងក្របខណ្ឌក្រុមការងារបច្ចេកទេសចម្រុះកម្ពុជា-ជប៉ុន ដើម្បីរៀបចំសេចក្តីព្រៀងក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។ ជាលទ្ធផលក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានដាក់អោយអនុវត្តជាផ្លូវការ នៅខែកក្កដា ឆ្នាំ២០០៧ និង ក្រមរដ្ឋប្បវេណីត្រូវបានគេអនុវត្តនៅខែធ្នូ ឆ្នាំ២០១១។ បច្ចុប្បន្ននេះ JICA កំពុងអនុវត្តគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការជំហានទី៤ (កិច្ចសហប្រតិបត្តិការបច្ចេកទេស) ជាមួយក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ គម្រោងនេះមានគោលបំណងក្នុងការលើកកម្ពស់សមត្ថភាពស្នូលនៃវិជ្ជាជីវៈច្បាប់ សំដៅអនុវត្ត និងផ្សព្វផ្សាយក្រមរដ្ឋប្បវេណី និងក្រមនិតិរដ្ឋប្បវេណីអោយបានសមស្រប នឹងមាននិរន្តរភាព។



*នំដូណាត់ធ្វើឡើងដោយស្ត្រីជនបទក្នុងខេត្តកំពង់ចាម (គម្រោងបញ្ជ្រាបយេនឌ័រ ដំណាក់កាលទី២)*

នៅក្នុងផ្នែករដ្ឋបាលសារធារណៈ JICA បានកំពុងជួយរៀបចំកំនែទម្រង់ជាតិអំពីវិមជ្ឈការនិងវិសហមជ្ឈការ តាមរយៈការពង្រឹងសមត្ថភាពលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍ តាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ គម្រោងអភិវឌ្ឍសមត្ថភាពសំរាប់អនុវត្តច្បាប់អង្គការនៅកម្រិតក្រុង និងខេត្ត(កិច្ចសហប្រតិបត្តិការបច្ចេកទេស) ផ្តល់ការគាំទ្រដល់លេខាធិការដ្ឋានគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍន៍តាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដើម្បីបង្កើតនិងអនុវត្តយន្តការសំរាប់ធ្វើផែនការអនុវត្ត និងតាមដាននូវផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងផែនការវិនិយោគរយៈពេល៣ឆ្នាំ ព្រមទាំងកសាងសមត្ថភាពរបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិកម្រិតខេត្ត។



*បុគ្គលិក NIS កំពុងប្រមូលពត៌មានពីផ្ទះមួយទៅផ្ទះមួយដើម្បីធ្វើជំរឿនសេដ្ឋកិច្ច*

JICAបានកំពុងផ្តល់ការគាំទ្រដល់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងក្រសួងកិច្ចការនារី។ វិទ្យាស្ថានជាតិស្ថិតិ និង JICA បានធ្វើជំរឿនប្រជាជនឆ្នាំ២០០៨ ជំរឿនសេដ្ឋកិច្ចឆ្នាំ២០១១ និងសកម្មភាពដទៃទៀត តាមរយៈគម្រោងធ្វើអោយប្រសើរឡើងនូវស្ថិតិផ្លូវការនៅប្រទេសកម្ពុជា (ដំណាក់កាលទី១ ដល់ទី៣) (កិច្ចសហប្រតិបត្តិការបច្ចេកទេស) ដែលផ្តល់ព័ត៌មានសំខាន់ៗសំរាប់ស្ថាប័នរដ្ឋ ដើម្បីបង្កើតនយោបាយអោយបានល្អ និងសម្រាប់អាជីវកម្មដើម្បីទទួលបានការយល់ដឹងអោយបានច្បាស់អំពីទីផ្សារ។ ក្រសួងកិច្ចការនារី និង JICAបានសហការជាមួយគ្នាយូរមកហើយដើម្បីជួយដល់ស្ត្រីនៅក្នុងប្រទេសកម្ពុជា និងជម្រុញសមភាពយេនឌ័រ នៅក្នុងគោលនយោបាយសារធារណៈ និងស្ថាប័នរដ្ឋនានា។ គម្រោងស្តីពីការបញ្ជ្រាបយេនឌ័រ (ដំណាក់កាលទី១និងទី២) (កិច្ចសហប្រិតិបត្តិការបច្ចេកទេស) បានចូលរួមចំណែកសម្រេចបាននូវគោលដៅទាំងនេះ ជាពិសេសការអនុវត្តគម្រោងសាកល្បង សម្រាប់ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនៅខេត្តកំពង់ចាម។ ចំណេះដឹងនិងបទពិសោធន៍ដែលទទួលបានពីគម្រោងសាកល្បងនេះនឹងពង្រឹងមុខងាររបស់ក្រសួងកិច្ចការនារី ព្រមទាំងសមត្ថភាព និងយន្តការរបស់ក្រសួងជាដៃគូដើម្បីសំរេចបានការបញ្ជ្រាបយេនឌ័រ តាមរយៈការអនុវត្តសកម្មភាពនានាសំដៅពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី។

## កម្មវិធីអ្នកស្ម័គ្រចិត្តរបស់ JICA

**វិស័យសំខាន់ៗសម្រាប់សកម្មភាព**
**អ្នកស្ម័គ្រចិត្តវ័យក្មេង**

ការអប់រំវិទ្យាសាស្ត្រ
ការអប់រំបឋមសិក្សា
ការអភិវឌ្ឍសហគមន៍
ការបណ្តុះបណ្តាលកុំព្យូទ័រ
បច្ចេកវិទ្យាមន្ទីរពិសោធន៍
សកម្មភាពយុវជន



*យុវជនស្ម័គ្រចិត្តជំនាន់ទី១នៅកម្ពុជា*
*គ្រូកីឡាហែលទឹក*



*យុវជនស្ម័គ្រចិត្តគ្រូបឋមសិក្សា*

**វិស័យសំខាន់ៗសម្រាប់សកម្មភាព**
**អ្នកស្ម័គ្រចិត្តវ័យចំណាស់**

អេឡិចត្រូនិច
គ្រឿងចក្រសាងសង់ធុនធ្ងន់
ការផលិតកម្មវិធីទូរទស្សន៍
កែច្នៃចំណីអាហារ
ទីប្រឹក្សាគោលនយោបាយអប់រំ
កីឡាអ៊ែគីដូ

### ចំនួនអ្នកស្ម័គ្រចិត្តដែលកំពុងបម្រើការនៅកម្ពុជា ៦៤៩នាក់ (វ័យក្មេង:៤៤៣ វ័យចំណាស់: ២០៦ ) គិតត្រឹមថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៥




កម្មវិធីសំរាប់អ្នកស្ម័គ្រចិត្តវ័យក្មេង ត្រូវបានគេផ្តួចផ្តើមឡើង នៅខែមេសា ឆ្នាំ១៩៦៥ ដោយការបង្កើតលេខាធិការដ្ឋានសម្រាប់អ្នកស្ម័គ្រចិត្តវ័យក្មេង ស្ថិតនៅជាផ្នែកមួយនៃភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ខាងកិច្ចសហការបច្ចេកទេស(អតីត JICA )។

សារជាផ្លូវការទ្វេភាគីរវាងរាជរដ្ឋាភិបាលជប៉ុន និងរាជរដ្ឋាភិបាលកម្ពុជា ស្តីអំពីការបញ្ជូនអ្នកស្ម័គ្រចិត្តមកកម្ពុជា បានចុះហត្ថលេខានៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៦៥ ដែលនាំទៅដល់ការបញ្ជូនជាលើកដំបូង នូវយុវជនស្ម័គ្រចិត្តចំនួនបួនរូបក្នុងវិស័យកីឡា និងកសិកម្ម មកធ្វើការនៅកម្ពុជា នៅថ្ងៃទី៩ ខែមករា ឆ្នាំ១៩៦៦។

កម្មវិធីនេះត្រូវបានបង្អាក់ នៅពេលផ្ទុះសង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា។ មានយុវជនស្ម័គ្រចិត្តសរុប១៦រូប នៅពេលនោះ ត្រូវបង្ខំចិត្តធ្វើមាតុភូមិនិវត្តន៍ទៅជប៉ុនវិញ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧០។

កម្មវិធីបញ្ជូនអ្នកស្ម័គ្រចិត្តមកកម្ពុជា ដែលកំពុងត្រូវបានគេអនុវត្តរហូតទល់បច្ចុប្បន្ននេះ ក្នុងគោលបំណងជម្រុញកិច្ចសហប្រតិបត្តិការបច្ចេកទេសរវាងកម្ពុជានិងជប៉ុន ផ្អែកលើការប្តូរសារជាផ្លូវការនៅឆ្នាំ១៩៩២។ នៅពេលនោះយុវជនស្ម័គ្រចិត្តចំនួនប្រាំរូបត្រូវបានគេបញ្ជូនសារជាថ្មីមកកម្ពុជា នៅចុងឆ្នាំ១៩៩២ ដើម្បីបំពេញការងារលើវិស័យអប់រំ សុខាភិបាល និងទេសចរណ៍។

នៅឆ្នាំ១៩៩៣ JICA បានបើកការិយាល័យរបស់ខ្លួននៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា ដើម្បីគ្រប់គ្រងជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ជប៉ុនក្នុងនោះមានការគ្រប់គ្រងកម្មវិធីអ្នកស្ម័គ្រចិត្តវ័យក្មេងផងដែរ។

ក្រោយមកកម្មវិធីបញ្ជូនអ្នកស្ម័គ្រចិត្តវ័យចំណាស់មកកម្ពុជា ត្រូវបានគេចាប់ផ្តើមនៅឆ្នាំ២០០១។ ចាប់តាំងពីឆ្នាំ១៩៩៤មក កម្មវិធីអ្នកស្ម័គ្រចិត្តទាំងពីរប្រភេទនេះ បានត្រូវគេស្គាល់ជាទូទៅថាជាផ្នែកមួយនៃសកម្មភាពសហប្រតិបត្តិការរបស់ JICA ។

កម្មវិធីអ្នកស្ម័គ្រចិត្តវ័យក្មេងប្រារព្ធខួប៥០ឆ្នាំនៃកិច្ចសហប្រតិបត្តិការរបស់ខ្លួននៅឆ្នាំនេះ។ ចាប់តាំងពីពេលដែលកម្មវិធីនេះចាប់ផ្តើមជាមួយនឹងកិច្ចសហការនឹងប្រទេស ឡាវ កម្ពុជា ម៉ាឡេស៊ី និងហ្វីលីពីនក្នុងឆ្នាំ១៩៦៥ កម្មវិធីបានបន្តឆ្លើយតបទៅនឹងតម្រូវការរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយបណ្តុះបណ្តាលនិងបញ្ជូនយុវជនស្ម័គ្រចិត្តមកចូលរួមចែករំលែកជំនាញ និងចំណេះដឹងក្នុងទីតាំងស្ថិតនៅ១៦ខេត្ត/ក្រុងរបស់កម្ពុជា។ យុវជនដែលមានអាយុពី២០ឆ្នាំដល់៣៩ឆ្នាំទាំងនោះ បានបំពេញបេសកម្មដែលមានរយៈពេលពីរឆ្នាំម្នាក់នៅក្នុងវិស័យសំខាន់ៗ ដូចជា អប់រំ សុខាភិបាល កសិកម្ម ទេសចរណ៍ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក្នុងរយៈពេលដូចគ្នានេះ JICA បានចាប់ផ្តើមកម្មវិធីស្ម័គ្រចិត្តស្រដៀងគ្នា។ នៅកម្ពុជាកម្មវិធីស្ម័គ្រចិត្តវ័យចំណាស់ដែលអ្នកចូលរួមមានអាយុពី៤០ឆ្នាំ ដល់៦៩ឆ្នាំ ត្រូវបានគេចាប់ផ្តើមនៅឆ្នាំ២០០១។

អ្នកស្ម័គ្រចិត្តជប៉ុនរស់នៅនិងធ្វើការជាមួយគ្នានឹងប្រជាជននៅមូលដ្ឋាន ដោយយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពទីពឹងខ្លួនឯងរបស់ប្រជាជន។

កម្មវិធីស្ម័គ្រចិត្តទាំងនេះផ្តោតលើការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច ដោយឈរលើកិច្ចសហការចេញពីសហគមន៍ដើម្បីកាត់បន្ថយភាពក្រីក្រ ពង្រឹងការគាំពារសុខភាព និងការអប់រំ និងដោះស្រាយបញ្ហាផ្សេងៗទៀត។

រហូតមកទល់សព្វថ្ងៃ មានអ្នកស្ម័គ្រចិត្តសរុបចំនួន៦៤៩រូប ត្រូវបានគេបញ្ជូនមកធ្វើការនៅប្រទេសកម្ពុជាស្ថិតក្នុងខេត្ត/ទីក្រុងចំនួន១៦។ សកម្មភាពអ្នកស្ម័គ្រចិត្តបានដើរតួនាទីជា ការងារការទូតប្រចាំមូលដ្ឋាន ក្នុងការជម្រុញការយល់ដឹងពីគ្នាទៅវិញទៅមករវាងកម្ពុជានិងជប៉ុន។

ខាងក្រោមគឺជាប្រវត្តិសង្ខេបក្នុងរយៈកាល៥០ឆ្នាំមកនេះនៃការស្ម័គ្រចិត្តជប៉ុននៅកម្ពុជា។

១៩៦៥ ពិធីប្តូរសាររវាងរាជរដ្ឋាភិបាលជប៉ុននិងកម្ពុជាលើកម្មវិធីអ្នកស្ម័គ្រចិត្តវ័យក្មេង។
១៩៦៦ ការបញ្ជូនយុវជនស្ម័គ្រចិត្តចំនួនបួនរូបលើកដំបូងក្នុងបេសកម្មនៅកម្ពុជា។
១៩៧០ យុវជនស្ម័គ្រចិត្តទាំងអស់ចាកចេញពីកម្ពុជាដោយសារសង្គ្រាមស៊ីវិល(មាន១៦រូប ក្នុងវិស័យកីឡានិងកសិកម្ម)។
១៩៩២ កម្មវិធីអ្នកស្ម័គ្រចិត្តវ័យក្មេងចាប់បន្តឡើងវិញ។យុវជន៥រូបត្រូវបានគេបញ្ជូនមកធ្វើការក្នុងវិស័យ អប់រំ សុខាភិបាល និងទេសចរណ៍។
១៩៩៣ ដំណើរការការិយាល័យទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុននៅរាជធានីភ្នំពេញ។គោលបំណងសំខាន់មួយនៃការបើកការិយាល័យនេះគឺដើម្បីសម្របសម្រួលកម្មវិធីអ្នកស្ម័គ្រចិត្ត។
២០០១ ការបញ្ជូនអ្នកស្ម័គ្រចិត្តវ័យចំណាស់ចំនួន១៥រូបលើកដំបូងមកបំពេញបេសកម្មនៅកម្ពុជា។
បច្ចុប្បន្ន អ្នកស្ម័គ្រចិត្តសរុប៦០រូប(ក្នុងនោះយុវជន៣៨រូប និងជនវ័យចំណាស់២២រូប)កំពុងបំពេញបេសកម្មនៅកម្ពុជា។

ឯកសារយោង៖ http://www.mofa.go.jp/policy/oda/guide/1998/2-6.html

## កម្មវិធីភាពជាដៃគូរបស់ JICA

ដើម្បីឆ្លើយតបនឹងតម្រូវការផ្សេងៗរបស់ប្រទេសកំពុងអភិវឌ្ឍន៍ JICA រៀបចំអនុវត្តកម្មវិធីភាពជាដៃគូរបស់ JICA ដោយមានការសហការជាមួយស្ថាប័នដៃគូនៅក្នុងប្រទេសជប៉ុនដូចជាអង្គការក្រៅរដ្ឋាភិបាលសកលវិទ្យាល័យអង្គភាពរដ្ឋាភិបាលមូលដ្ឋាននិងក្រុមហ៊ុនសាជីវកម្មដែលបម្រើផលប្រយោជន៍ដល់សាធារណៈ ដែលមានចំណេះដឹងជំនាញ និងធនធានមនុស្សប្រកបដោយវិជ្ជាជីវៈ។ នៅក្នុងប្រទេសកម្ពុជា រហូតដល់ពេលនេះ គម្រោងចំនួន៤០ត្រូវបានអនុវត្ត ហើយគម្រោងទាំងនេះបានចូលរួមចំណែកដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចចាប់ពីកម្រិតសហគមន៍ឡើងទៅ។

### ករណីសិក្សាទី១

**សកលវិទ្យាល័យណាហ្គោយ៉ា**

*គម្រោងលើកកម្ពស់សុវត្ថិភាពផលិតផលអាហារកែច្នៃពីកសិកម្មនៅកម្ពុជា*
*( តាកែវ កំពង់ស្ពឺ កណ្តាល និងខេត្តដទៃទៀត / ២០១៤ដល់ឆ្នាំ២០១៩ )*


វគ្គបណ្តុះបណ្តាលអំពីការផលិតស្រានៅនឹងកន្លែង

គម្រោងនេះយកចិត្តទុកដាក់លើការផលិត និងលក់បន្លែ និងផលិតផលកែច្នៃពីកសិកម្មដទៃទៀតរបស់កម្ពុជាប្រកបដោយសុវត្ថិភាព។ គម្រោងផ្តោតលើការបណ្តុះបណ្តាលផលិតករស្រាអង្ករ ដែលអាចផលិតស្រាអង្ករប្រកបដោយគុណភាពខ្ពស់ និងមានសុវត្ថិភាពនៅក្នុងខេត្តតាកែវ និងពង្រឹងការយល់ដឹងអំពីការប្រើប្រាស់ជាតិមេតាណុលលើសចំនុះក្នុងផលិតកម្មស្រាអង្ករ ដល់អ្នកផលិតនិងអតិថិជនក្នុងតំបន់ផលិតស្រាអង្ករទាំងឡាយ។ ចំណែកខាងបន្លែវិញ គម្រោងបានលើកយកស្តង់ដារសុវត្ថិភាពជប៉ុន មកបណ្តុះបណ្តាលអ្នកដាំបន្លែទាំងឡាយ និងជួយរកទីផ្សារក្នុងស្រុកដែលត្រូវការបន្លែទាំងនោះ។ ចំណេះដឹងទទួលបានពីការសហការទាំងនេះត្រូវបានចងក្រងទុកនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម សម្រាប់ប្រើប្រាស់ទូលំទូលាយដល់អ្នកត្រូវការទាំងឡាយនាពេលអនាគត។

### ករណីសិក្សាទី២

**គម្រោងកាម៉ូណូហាស៊ី**

*គម្រោងមូលដ្ឋានភារូបនីយកម្មរោងចក្រសហគមន៍ ដើម្បីលើកកម្ពស់ស្ថានភាពស្រ្តីទីទ័លក្រតោកយ៉ាក*
*( សៀមរាប /២០១៣ដល់ឆ្នាំ២០១៧ )*


អ្នកផលិតទាំងអស់សប្បាយរីករាយនឹងការងារក្នុងមណ្ឌលសហគ្រាសសហគមន៍

គម្រោងនេះបង្កើតឡើងនៅឆ្នាំ២០០៨ សម្រាប់រោងចក្រនៅសហគមន៍មួយដែលផលិតទំនិញកែច្នៃដោយដៃពីដំណាំរុក្ខជាតិមននៅស្រុកសូទ្រនិគម ក្នុងខេត្តសៀមរាប។ រោងចក្រផ្តល់ឱកាសការងារដល់ស្រ្តីក្រីក្រតោកយ៉ាក និងលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចរបស់ក្រុមគ្រួសារពួកគេ។ ក្រៅពីការងារស្ថិតស្ថេរ និងប្រាក់ចំណូលជាប្រចាំ គម្រោងបានជួយដល់ស្រ្តីទាំងនោះអោយមានបំណិតជីវិតជាក់លាក់ មានប្រយោជន៍ដល់ការរស់នៅរាល់ថ្ងៃរបស់ពួកគេ។

គម្រោងមានគោលបំណងផ្ទេរការកាន់កាប់សកម្មភាពរោងចក្រសហគមន៍នេះមកកម្ពុជាតាមរយៈការបង្កើតកម្មវិធីអន្តរាគមន៍សេវាសង្គមសម្រាប់ស្រ្តី និងក្រុមគ្រួសារពួកគេ សូចនាករតាមដានប្រសិទ្ធភាពនៃកម្មវិធីនេះ និងការផ្ទេរការគ្រប់គ្រងរោងចក្រទៅបុគ្គលិកកម្ពុជា តាមរយៈការពង្រឹងសមត្ថភាពក្រុមអ្នកគ្រប់គ្រងកម្ពុជា។

## ភាពជាដៃគូ និងការសម្របសម្រួលជំនួយ

JICA ផ្តល់តម្លៃនិង លើកកម្ពស់ការងារភាពជាដៃគូ និងភាពប្រទាក់ក្រឡាគ្នានៅក្នុងហរិញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ។ ក្នុងប្រទេសកម្ពុជា JICA ចូលរួមយ៉ាងសកម្មនៅក្នុងការពិភាក្សា និងសហប្រតិបត្តិការជាមួយដៃគូផ្សេងទៀត ក្រោមយន្តការសហប្រតិបត្តិការដែលបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។ JICA គឺជាសមាជិកដ៏សកម្មរបស់ក្រុមការងារបច្ចេកទេសចម្រុះជាច្រើនដែលមានការសហការរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា និងដើរតួជាអ្នកសម្របសម្រួលដឹកនាំ សម្រាប់ក្រុមការងារបច្ចេកទេសចម្រុះចំនួន ០២ គឺក្រុមការងារបច្ចេកទេសចម្រុះលើវិស័យហេដ្ឋារចនាសម្ព័ន្ធនិង សមាហរណកម្មតំបន់ និងវិស័យយេនឌ័រ។ នៅកម្រិតគម្រោងការពិភាក្សានិងការសម្របសម្រួលទ្វេភាគីធ្វើឡើងរៀងរាល់ថ្ងៃនិងនៅពេលមានតម្រូវការ។ កិច្ចប្រជុំទៀងទាត់ត្រូវបានធ្វើឡើងជាមួយដៃគូអភិវឌ្ឍន៍ដែល JICA កំពុងធ្វើការជាមួយយ៉ាងជិតស្និទនៅក្នុងវិស័យដូចគ្នាដើម្បីផ្លាស់ប្តូរព័ត៌មាន និងពិភាក្សាអំពីទិសដៅនៃសហប្រតិបត្តិការ និងការសម្របសម្រួលប្រកបដោយចីរភាព។


បង្គោលសម្រាប់បណ្តាញចែកចាយអគ្គិសនីនៅទីតាំងគម្រោង

JICA ក៏បានអនុវត្តគម្រោងសហហរិញ្ញប្បទានដូចជា គម្រោងផ្គត់ផ្គង់ទឹកស្អាតនិរោធន៍ ( កម្ចីសម្បទានចំនួន៣.៥១៣លានយ៉េន ) ដោយធ្វើហរិញ្ញប្បទានស្របទិសគ្នាជាមួយទីភ្នាក់ងារអភិវឌ្ឍន៍ប្រទេសបារាំង និងគម្រោងអភិវឌ្ឍន៍បណ្តាញថាមពលមហាតំបន់ទន្លេមេគង្គ ( កម្ចីសម្បទានចំនួន២.៦៣២លានយ៉េន ) ជាមួយធនាគារអភិវឌ្ឍន៍អាស៊ី។

ក្នុងពេលថ្មីៗនេះ JICA ត្រូវបានគេដឹងយ៉ាងទូលំទូលាយថាបានឈានហួសពីការផ្តល់ហរិញ្ញប្បទាន សហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការទៅទៀត ដោយបានចាប់ផ្តើមធ្វើការងារយ៉ាងជិតស្និទជាមួយវិស័យឯកជន ជាពិសេសរួមមានអ្នកវិនិយោគជប៉ុននិងសមាគមអាជីវកម្មជប៉ុនប្រចាំកម្ពុជា និង ក្រុមសង្គមស៊ីវិល។ សព្វថ្ងៃនេះ ភាពជាដៃគូ និងការសម្របសម្រួលកាន់តែមានសារៈសំខាន់ខ្លាំងឡើងៗសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ប្រកបដោយភាពជោគជ័យ។ លើសពីនេះ ការិយាល័យ JICA ប្រចាំកម្ពុជា ប្តេជ្ញាធ្វើការងារក្នុងភាពជាដៃគូល្អជាមួយដៃគូនិងអ្នកពាក់ព័ន្ធផ្សេងៗទៀត។


រោងចក្រប្រព្រឹត្តកម្មទឹកស្អាតនៅនិរោធន៍



*ស្ពាន ត្សឹបាសា (ស្ពានអ្នកលឿង) (ថតរូបដោយ អាយ៉ាគុរ គីមឹរា)*


## JICA Cambodia Office

### JICA Plaza Cambodia

P.O. Box 613, 6th-8th floors, Building #61-64,
Preah Norodom Blvd, Phnom Penh, Cambodia
TEL: +855-(0)23-211673 FAX: +855-(0)23-211675
Email: cm_oss_rep@jica.go.jp
http://www.jica.go.jp/english


From
the People of Japan

Published in December 2015.